# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សេង ហៀង

*សម្ភាសជាមួយ **សេង ហៀង** ភេទប្រុស អាយុ ៥៦ឆ្នាំ*

*នៅភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ*

*នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៤*

*សម្ភាសដោយៈ ញាណ សុជាតិ*

សុជាតិៈ ..........គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានពីរទីមួយគឺប្រមូលកងក្រង ពត៌មានដែលបានមកពីការសម្ភាសន៍ពូនិងដើម្បីចងក្រងឲ្យក្មេងជំនាន់ក្រោយបានដឹង ហើយមួយទៀតពត៌មាននិងអាចជាភស្តុតាងខាងផ្លូវច្បាប់នៅពេលដែលមានតុលាការ ព្រោះអីឥឡូវនិងមានមនុស្សមួយចំនួនមិនជឿថាសម័យខ្មែរក្រហមនិងមិនការ សម្លាប់មនុស្សទេ ដល់ពេលអញ្ចឹងហើយទើបយើងខ្ញុំចុះមកសួរនេះថា ទៅសួរប្រជា ជនមើល តើមានការសម្លាប់មនុស្សអត់? ប្រជាជនថាមាននិងជាភស្តុតាងមួយដែរ ហើយខ្ញុំចុះមកនិងមានគំរោងមួយដែលគេហៅថាគំរោងជួយជនរងគ្រោះដោយអំពើ ទារុណកម្ម គំរោងនិងគឺមានគោលបំណងពីរដែរគឺប្រមូលចងក្រងពត៌មានសំរាប់ក្មេង ជំនាន់ក្រោយបានដឹងបានលឺ ហើយមួយទៀតបើសិនជាសួរនាំទៅឃើញថាពូមានជំ នឺ មានវិបត្តផ្លូវចិត្តដោយសារតែគេយកឪពុកម្តាយទៅសម្លាប់អីអញ្ចឹង ខាងខ្ញុំបាន សហការជាមួយអង្គការមួយទៀតហើយអង្គការនិងអាចមកជួយពូបានបើសិនជា ពិនិត្យឃើញថា ពូមានវិបត្តផ្លូវចិត្ត។ គេអាចជួយពូជាថ្នាំពេទ្យផង ផ្តល់ជាទីប្រឹក្សា ផងដើម្បីឲ្យជំងឺនិងធូរស្រាលឡើងវិញណាពូ អញ្ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូសិនតើ ពូមានឈ្មោះអីដែរ?

ហៀងៈ បាទ ខ្ញុំឈ្មោះសេង ហៀង

សុជាតិៈ ពូមានអាយុប៉ុន្មានហើយ?

ហៀងៈ អាយុ ៥៦ឆ្នាំ

សុជាតិៈ ពូមានស្រុកកំណើតនៅភូមិណាដែរ?

ហៀងៈ នៅភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ

សុជាតិៈ សព្វថ្ងៃពូរស់នៅភូមិអីដែរ?

ហៀងៈ ដូចគ្នា ភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ

សុជាតិៈ សព្វថ្ងៃពូប្រកបមុខរបរអីដែរ?

ហៀងៈ ឥឡូវរបបររកស៊ីធ្វើស្រែ

សុជាតិៈ ចុះកាលពីមុនពូធ្វើអី?

ហៀងៈ ពីមុនធ្វើការនៅសាលាស្រុកត្រាំកក់

សុជាតិៈ អញ្ចឹងពូទើបតែចូលនិវត្តិទេហេះ?

ហៀងៈ បាទ ខ្ញុំចូលនិវត្តនៅថ្ងៃទី ១ ខែ ៤ ឆ្នាំ ២០០៤

សុជាតិៈ ពូ! ពូមានចាំទេថាពូរៀបការនៅឆ្នាំណាដែរ?

ហៀងៈ ឆ្នាំ ១៩៧២

សុជាតិៈ ចុះគ្រួសារពូឈ្មោះអីដែរ?

ហៀងៈ ឈ្មោះកែវធឿន

សុជាតិៈ គាត់មានអាយុប៉ុន្មានហើយ?

ហៀងៈ អាយុ ៥០ឆ្នាំ

សុជាតិៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ហៀងៈ បាទ កូនចៅ ៥នាក់

សុជាតិៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហៀងៈ ប្រុស២ ស្រី៣

សុជាតិៈ ក្នុងចំណោម៥នាក់និង តើប៉ុន្មាននាក់ដែលកើតទាន់ជំនាន់ប៉ុលពត?

ហៀងៈ ជំនាន់ប៉ុលពតអត់មានទេ

សុជាតិៈ អញ្ចឹងកូនទាំង៥នឹងកើតក្រោយ៧៩ទាំងអស់

ហៀងៈ បាទ

សុជាតិៈ ចុះឪពុកម្តាយពូដែលខ្មែរក្រហមយកទៅសម្លាប់និងឈ្មោះអីដែរ?

ហៀងៈ ឈ្មោះ សួ ពត

សុជាតិៈ កាលនិងគាត់អាយុប៉ុន្មាន?

ហៀងៈ អាយុ៧៦ឆ្នាំ ពេលនោះប៉ុលពតយកទៅ

សុជាតិៈ ចុះឪពុករបស់ពូ?

ហៀងៈ ឪពុកខ្ញុំឈ្មោះសេង ទ្រី ជាប់គុក

សុជាតិៈ កាលគេដាក់គុកគាត់និងគាត់អាយុប៉ុន្មានដែរ?

ហៀង៖ អាយុ ៦៥ឆ្នាំ

សុជាតិ៖ កាលនិងគាត់ធ្វើការអីពូ?

ហៀង៖ គាត់ជាប្រជាជន គេបែងចែក

សុជាតិ៖ ហេតុអីបានជាគេបែងចែក?

ហៀង៖ គេបែកចែកវណ្ណៈ គេថាយើងពីសក្តមវណ្ណៈជាអ្នកគ្រាន់បើអញ្ចឹងទៅ

សុជាតិ៖ តែអត់មានជាប់សាច់ឈាមអីអ្នកមកពីភ្នំពេញអីទេហេះ?

ហៀង៖ អត់មានទេ គេបែកចែកវណ្ណៈ

សុជាតិ៖ អញ្ចឹងពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ហៀង៖ ខ្ញុំមានបងប្អូន២នាក់

សុជាតិ៖ ប្រុសមួយរឺប្រុសទាំងអស់?

ហៀង៖ ប្រុសមួយស្រីមួយ

សុជាតិ៖ ពូបងគេរឺប្អូនគេ?

ហៀង៖ ខ្ញុំជាប្អូន បងស្រីនៅភ្នំពេញ

សុជាតិ៖ អូ! ឥឡូវគាត់នៅភ្នំពេញ?

ហៀង៖ បាទ

សុជាតិ៖ អញ្ចឹងគ្រួសារពូមានបងប្អូន២នាក់ ឪពុកមួយម្តាយមួយនិង តើបាត់បងប៉ុន្មាននាក់ដែរ?

ហៀង៖ បាត់បង់ពីរនាក់ បងថ្លៃមួយនិងម្តាយមួយ

សុជាតិ៖ ចុះឪពុក ?

ហៀង៖ ឪពុកជាប់គុកតែរួច បងខ្ញុំបង្កើតក៏ជាប់ដែរតែរួចមកវិញ

សុជាតិ៖ អញ្ចឹងបាត់បង់តែម្តាយពូមួយទេអញ្ចឹង?

ហៀង៖ បាទ

សុជាតិ៖ គាត់យ៉ាងម៉ិចពូ ម្តាយពូស្លាប់ដោយសារអីដែរ?

ហៀង៖ គេបែងចែកវណ្ណៈ និងគេចែកតែម្តង

សុជាតិ៖ គេចោទថាម៉ិចកាលនិង?

ហៀង៖ គេចោទថាជាគិញអាមេរិកាំងអញ្ចឹងទៅ

សុជាតិ៖ ចុះពូថាគាត់ចូកដានដើងអីនោះយ៉ាងម៉ិច?

ហៀង៖ កាលនិងគេចោទ គេមកដាក់ចបនៅនិងផ្ទះខ្ញុំនិង ហើយ............

សុជាតិៈ កាលនិងឆ្នាំប៉ុន្មានពូ?

ហៀងៈ ឆ្នាំ ១៩៧៥

សុជាតិៈ កាលនិងបែកភ្នំពេញនៅពូ?

ហៀងៈ បែកហើយ

សុជាតិៈ បែកបានប៉ុន្មានខែ?

ហៀងៈ បែកបានប្រហែលជា២-៣ខែនិង

សុជាតិៈ កាលនិងគាត់អត់មានធ្វើការអីទេពូហេះ?

ហៀងៈ អត់ទេ គាត់ជាប្រជាជន

សុជាតិៈ អញ្ចឹងពូ ពេលដែលរដ្ឋប្រហារលន់ណុលឆ្នាំ៧០និង ពូមានចាំទេពូធ្វើអីដែរកាល និង?

ហៀងៈ ខ្ញុំជាប្រជាជន អត់មានធ្វើអីទេ

សុជាតិៈ ពូអត់រៀនអីទេ?

ហៀងៈ អូ! ខ្ញុំរៀន

សុជាតិៈ ពូរៀនដល់ថ្នាក់ណាដែរ?

ហៀងៈ រៀនដល់ថ្នាក់ទី៧

សុជាតិៈ កាលនិងពូរៀននៅសាលាណា?

ហៀងៈ សាលាចឹកជ្រុំយើងនិង

សុជាតិៈ ពូពេលរដ្ឋប្រហារនិង តើនៅភូមិរបស់ពូរឺនៅអង្គតាសោមមានអីកើតឡើងខ្លះ?

ហៀងៈ កាលនិងវា.....

សុជាតិៈ មានបាតុកម្មអី រឺមានចោរព្រៃអីគេមកទេ

ហៀងៈ អត់ទេ មានប៉ុលពត

សុជាតិៈ មានប៉ុលពតតែម្តង?

ហៀងៈ បាទ

សុជាតិៈ កាលនិងគេចុះមកដំបូងគេធ្វើរបៀបម៉ិចពូ?

ហៀងៈ គេចុះមកគេចងក្រងជាក្រុមអ្នកយកតាមវណ្ណៈ វណ្ណៈអ្នកក្រគេគ្រប់គ្រងយើង

សុជាតិៈ គេបែកចែករបៀបម៉ិច យ៉ាងម៉ិចដែលចូលជាវណ្ណៈទី១ វណ្ណៈទី២......?

ហៀងៈ គេថាអ្នកដែលគ្មានការពាក់ព័ន្ធ គ្មានបងប្អូនអតីតរដ្ឋការចាស់ទី២វណ្ណៈអ្នកក្រ ហើយ អ្នកមិនសូវចេះ

សុជាតិៈ និងវណ្ណៈទី១ហើយនិងហេះ?

ហៀង៖ បាទ វណ្ណៈទី១

សុជាតិ៖ ហើយកាលនិងពូរៀនបានចេះដឹងខ្លះដែរ ហើយគេចាត់ចូលវណ្ណៈទី២

ហៀង៖ បាទ ពាក់ព័ន្ធ

សុជាតិ៖ វណ្ណៈទី១ និង ទី២ ខុសគ្នាយ៉ាងម៉េចពូ គេឲ្យធ្វើការខុសគ្នាយ៉ាងម៉េច?

ហៀង៖ ខុសគ្នាត្រង់ថា ប្រភេទទី១គេគ្រប់គ្រងយើងជាក្រុមទេណា ជាកងអញ្ចឹងទៅ ហើយទី២គេអត់ឲ្យយើងជាកងអីទេ គេឲ្យយើងធ្វើពលកម្មសុទ្ធ កាប់ប្រឡាយអីអញ្ចឹងទៅណា៎

សុជាតិ៖ បាទ គេឲ្យធ្វើពលកម្មនិងតាំងពីឆ្នាំណាមក?

ហៀង៖ ពលកម្មនិងឆ្នាំ៧៣?

សុជាតិ៖ តាំងពី៧៣មកគេឲ្យធ្វើពលកម្មរហូត?

ហៀង៖ បាទ ពលកម្មជីកប្រឡាយអីរហូតមក ៧៣-៧៤-៧៥និងរហូតទើបដល់៧៩

សុជាតិ៖ អូ! តាំងពីយូរមកហើយ

ហៀង៖ បាទ

សុជាតិ៖ ហើយកាលនិងគេឲ្យហូបរួមហើយរឺនៅពូ ៧២-៧៣និង?

ហៀង៖ នៅទេ គេបែកជាក្រុម ទាល់តែដល់ឆ្នាំ៧៦-៧៧គេបែកតាមក្រុមតាមកងវិញ ហើយ

សុជាតិ៖ ចុះកាលនិងខ្ញុំចង់ដឹងថា ពេលដែលខ្មែរក្រហមចូលមកដំបូងគេធ្វើយ៉ាងម៉េចពូ គេគំរាមយើងរឺគេលួងលោមយើងដែរ?

ហៀង៖ គេអត់មានគំរាមយើងអីទេ អានិងគេប្រមូលផ្តុំ មុនដំបូងគេថាប្រមូលផ្តុំ រៀបចំជាក្រុម រកអ្នកពេញសិទ្ធៗ អ្នកពេញសិទ្ធដូចខ្ញុំនិយាយខាងលើអញ្ចឹងថា តាមវណ្ណៈនិងតាមប្រភេទដែលគ្មានការពាក់ព័ន្ធ អានិងគេអាចគ្រប់គ្រងយើង ហើយចុងក្រោយមកគេបែកបែកហើយ

សុជាតិ៖ អញ្ចឹងមានន័យថា ខ្មែរក្រហមចូលកាន់កាប់ភូមិពូ និងឆ្នាំណាដែរ?

ហៀង៖ ប៉ុលពតចូលកាន់កាប់ឆ្នាំ ៧០និងតែម្តង

សុជាតិ៖ អញ្ចឹងរដ្ឋប្រហារហើយមានប៉ុលពតតែម្តង? ស

ហៀង៖ បាទ រដ្ឋប្រហារហើយមានប៉ុលពតចូលមក

សុជាតិ៖ ចូលមកដំបូងគេធ្វើយ៉ាងម៉េច គេសម្លាប់ប្រធានភូមិអីអត់ទេ?

ហៀង៖ អត់ទេ អត់មានសម្លាបមនុស្សទេ មុនដំបូងដូចជាមេឃុំចាស់អីទៅ គេប្រមូលត្រាអីទៅ

សុជាតិៈ អូ! ប្រមូលគ្រាសិន

ហៀងៈ បាទ ប្រមូលគ្រា គ្រាមេឃុំ ឆ្នាំ៧០ គេប្រមូលនិង ហើយនិងការរៀបចំជាបណ្តើរ ៗរបស់គេអញ្ចឹង

សុជាតិៈ ហើយគេចូលភូមិនិង ប្រជាជនអត់មានធ្វើបាតុកម្មអីទេពូហេះ?

ហៀងៈ អត់ទេ អត់ហ៊ាន

សុជាតិៈ គេមានកាំភ្លើងអីដែរពូហេះ?

ហៀងៈ បាទ មានកាំភ្លើង

សុជាតិៈ ហើយទាហានលន់ណុលអត់មានមកអីទេហេះ?

ហៀងៈ លន់ណុលអត់មានមកដល់និងទេ ត្រឹមអង្គតាសោម

សុជាតិៈ ចុះខ្ញុំលឺថាកាលនិងដូចជាមានបាតុកម្មនៅអង្គរតាសោមហេះ ពូមានដឹងទេ?

ហៀងៈ បាតុកម្មពេលរដ្ឋប្រហារទេ ដល់ក្រោយមកទៀតអត់ទេ

សុជាតិៈ ពូ មានដែលត្រូវគេជន្លៀសទៅកន្លែងណាទេចេញពីភូមិដែរទេ?

ហៀងៈ ខ្ញុំគេអត់មានឲ្យនៅនេះទេ

សុជាតិៈ ពូទៅនៅឯណាវិញ?

ហៀងៈ ខ្ញុំទៅនៅភូមិតាប៉ែននេះដីប្រហែលជា១គីឡូ

សុជាតិៈ កាលនិងគេជន្លៀសពូនៅឆ្នាំណា?

ហៀងៈ ឆ្នាំ ៧៦ ផ្ទះនេះគេឡៃឡុង គេគ្រប់គ្រងទៅ

សុជាតិៈ កាលនិងគេឲ្យនរណាគេនៅ?

ហៀងៈ ប្រធានកង គេដាក់ជាកន្លែងពាណិជ្ជកម្ម រឺគេដាក់ឲ្យអ្នកពេញសិទ្ធ គេអត់មានឲ្យយើងនៅទេ

សុជាតិៈ អញ្ចឹងពូចិញពី៧៦រហូតតាំងពីពេលនិងទៅ?

ហៀងៈ បាទ រហូតដល់ឆ្នាំ ៧៩និងតែម្តង វៀតណាមចូលមកនិង

សុជាតិៈ ចុះកាលនិងគេមានធ្វើប្រវត្តិរូបពូទេ?

ហៀងៈ កាលនិងខ្ញុំដាក់ធ្វើការខ្ញុំដាក់នៅភូមិនេះ

សុជាតិៈ អត់ទេ ពេលដែលខ្មែរក្រហមចូលមកគេមានសួរប្រវត្តិរូបពូទេ?

ហៀងៈ អត់ទេ គេភ្លាប់បានអស់ហើយ ដូចខ្ញុំបានជំរាបអញ្ចឹង គេសួរតាមថ្នាក់ក្រុមថ្នាក់កងរបស់គេ គេសួរស្រាវជ្រាវតាមមូលដ្ឋាន

សុជាតិៈ អញ្ចឹងភូមិរបស់ពូគេឲ្យហូបរួមដំបូងឆ្នាំណាដែរពូ?

ហៀង៖ ៧៦

សុជាតិ៖ ចុះគេឲ្យហូបរួមតាមក្រុមឆ្នាំណាដែរ?

ហៀង៖ អានិងតាមកងតែម្តង........

សុជាតិ៖ ឆ្នាំ ៧៦និងគេឲ្យហូបរួមទាំងអស់តែម្តង?

ហៀង៖ បាទ រួមទាំងអស់ ដុះតែមួយ

សុជាតិ៖ ចុះពូនៅរួម ហូបរួមនិងអីនិងមានសភាពយ៉ាងម៉ិចដែរពូ?

ហៀង៖ ហូបរួមនិងគ្មានប្រហុកអីទេ យើងខ្វះខាតអីទៅរកអំបិលអីគេមិនបាន ហើយយើងមានចំណីអីដូចជាបុកក្រសាំងអីគេអត់ឲ្យយើងហូបដែរ បាយយើងសុំគេ ដូចថាអ្នកចាស់ជរា ក្មេងតូចៗងក់ពេលនោះ ។ ពេលនោះយើងគ្មានបានបាយងហូបពេលភ្លឺឯណា ពេលយប់ម៉ោង១០ កូនអាយុ២-៣ឆ្នាំក៏សុំបាយគេមិនបានដែរ ហេតុនេះមានភាពវេទនាជាងគេបំផុតមកលើគ្រួសារដែលមានការពាក់ព័ន្ធ

សុជាតិ៖ គ្រួសារអ្នកពាក់ព័ន្ធនិងច្រើនទេពូ?

ហៀង៖ នៅក្នុងភូមិនេះដូចជាប្តីអ៊ុំនេះ គេយកទៅសម្លាប់នៅក្រាំងតាចាន់ផ្ទាល់ គាត់ជាអតីតគ្រូបង្រៀននៅខាងក្នុង ខាងលន់ណុល

សុជាតិ៖ ចុះកាលនិងភូមិសំប៊ួនិងគេចាត់ពូឲ្យធ្វើអីខ្លះកាលនិង?

ហៀង៖ ខ្ញុំអត់មានធ្វើអីទេ គេចាត់ឲ្យនៅតាមកងនិងតែម្តង

សុជាតិ៖ ធ្វើអីតាមកងនិងពូ?

ហៀង៖ តាមកងជីកប្រឡាយរែកដី រែកដីអញ្ចឹងទៅ រែកដីអញ្ចឹងទៅ ជាពិសេសប្រឡាយ

សុជាតិ៖ ចុះអ្នកមូលដ្ឋានគេឲ្យធ្វើអីដែរពូ?

ហៀង៖ មូលដ្ឋានគេឲ្យធ្វើការងារស្រាលៗ ដូចគ្រប់គ្រងយើងអញ្ចឹងទៅ ដូចជាត្រួតមើលគេឲ្យធ្វើការម្ហូប ធ្វើប្រធាន ធ្វើការស្រាលៗអញ្ចឹងទៅ ហើយបាយ ថ្នាក់ត្រឹមប្រធានក្រុម ប្រធានកងធំៗ គេមិនហូបបបរជាមួយយើងទេគេមានអង្ករ ម្ហូបអាហាររបស់គេ ដូចនេះគេធ្វើអញ្ចឹងគេធ្វើអញ្ចឹង គេហូបបាយអីទៅ ហើយយើងពាក់ព័ន្ធនឹប្រជាជនសុទ្ធដែលក្នុងប្រភេទពាក់ព័ន្ធអញ្ចឹងគេឲ្យហូបបបរនិងហើយ បបរជាមួយព្រលិត ត្រកួនអញ្ចឹងទៅ

សុជាតិ៖ អញ្ចឹងអ្នក១៧មេសានិងអ្នកជាប់ពាកព័ន្ធដូចពូអញ្ចឹងខុសគ្នាយ៉ាងម៉ិចដែរពូ?

ហៀង៖ ដូចគ្នាខ្ញុំ ក្នុងប្រភេទរបស់ខ្ញុំជាអ្នកមូលដ្ឋានមែន តែក្នុងសភាពទី៣ដូចគ្នា មានការពាក់ព័ន្ធ

សុជាតិៈ អញ្ចឹងក្រោយពីវៀតណាមចូលឆ្នាំ៧៩ពូមានរត់ចេញពីភូមិសំបូរទៅភូមិណាទៀតទេ មុននិងមកនិង?

ហៀងៈ ខ្ញុំអត់មានរត់ទេ ពេលដែលចេញពីនិង ខ្ញុំគ្រាន់តែរត់អញ្ចឹងទៅ គេពីប្រធានកង រត់មកតាមព្រៃអញ្ចឹងទៅ រួចខ្ញុំចូលមកវិញមក

សុជាតិៈ នៅព្រៃណាកាលនិង?

ហៀងៈ នៅព្រៃជិតៗនិង ចេះតែពួនទៅ ពួនសំងំទៅ

សុជាតិៈ យូរទេពូពេលដែលវៀតណាមចូលមកនិង?

ហៀងៈ ពេលដែលវៀតណាមចូលមកខ្ញុំចុះមកនិងតែម្តងទៅ

សុជាតិៈ អញ្ចឹងដល់ពេលពេលដែលជួបជុំគ្នាវិញ មកភូមិវិញ ពូជួបជុំគ្រួសារប៉ុន្មាននាក់ដែរ?

ហៀងៈ ជួបជុំទាំងអស់ បាត់ដែរ ដូចខ្ញុំបានជំរាបអញ្ចឹងថាគេសម្លាប់តែម្តាយទេ អត់មានបាត់ទេ បាត់បងថ្លៃមួយ និងបងថ្លៃគេយកទៅសម្លាប់និង ប្តីគាត់នោះគេយកទៅសម្លាប់នៅក្រាំងតាចាន់និង

សុជាតិៈ អញ្ចឹងពូ ពេលដែលជំនាន់ប៉ុលពតនិង ពូមានដែលខ្វះខាតម្ហូបអាហារអីដែរពូហេះ?

ហៀងៈ ហ៊ឺវេទនាណាស់ ជំនាន់ប៉ុលពតនិង ខ្ញុំបានជំរាបហើយថា ជំនាន់ប៉ុលពតនិងវេទនាបំផុតគឺហូបបបរនិងតែម្តង គេបែងចែក កំណត់ឆ្នាំង គ្មានបានហូបគ្រប់គ្រាន់ទេ

សុជាតិៈ មានដែលមានពេលណាមួយឆ្អែតទេពូ?

ហៀងៈ អត់ទេ អត់មានពេលទេ ធ្វើការយ៉ាងណាក៏ដោយ តែវីជ្វងគឺបានតែមួយចានសុទ្ធបបរជាមួយព្រលិត សាបភ្លេម ចង់រកជាតិប្រៃ រឹចង់ចូលរោងបាយវាអត់បានទេ សុំបាយវាថា កូនខ្ញុំងក់អាយុ២-៣ខួបអញ្ចឹងទៅ សុំបាយវាក៏វាមិនឲ្យហូបដែរ ហើយប់ឡើងនៅផ្ទះយើងតែមានភ្លើងមានដុត កាលនិងគេដុតប្រឡុះណ៎ ដុតជ័រ ដុតអីវាមកលូនស្តាប់ ឈ្លប់របស់វា យើងថាម៉ិចថា វេទនាបែកបែកគេថាក្នុងប្រភេទយើងមានការពាក់ពន្ធ គេតាមដានយើងតែម្តង

សុជាតិៈ ចុះពូមានដែលឃើញអ្នកដទៃទៀតគេអត់ដូចពូអញ្ចឹងដែរទេ?

ហៀងៈ អ្នកដទៃខ្ញុំដែរ ខ្ញុំនៅជាមួយអ្នក១៧ដូចតែគ្នា គេបែកចែកអ្នកមូលដ្ឋានជាប្រភេទទី២ តែគេដាក់ក្នុងដូចប្រភេទទី៣ ធ្វើការជាមួយប្រភេទទី៣ គេមានកងគេដាក់នៅនិងតែម្តង គេឲ្យយើងចូលក្នុងប្រភេទ១៧ទាំងអស់

សុជាតិៈ ចុះពូមានដែលលឺនៅកងផ្សេងគេអត់អាហារអីអញ្ចឹងដែរទេ?

ហៀងៈ គេមានកងពេញសិទ្ធរបស់គេ គេហូបគ្រប់គ្រាន់

សុជាតិៈ ចុះអ្នកដែលមានសមាសភាពដូចពូហើយនៅកងផ្សេង ពូមានដែលលឺថាគេហូបដូចពូដែលទេ?

ហៀងៈ ដូចគ្នា ដូចថាក្នុងកង១៧អីអញ្ចឹងទៅ និងកងមូលដ្ឋានដែលពាក់ព័ន្ធ

សុជាតិៈ ចុះពូកាលពីជំនាន់ប៉ុលពតនិងពូមានដែលឈឺថ្កាត់ដោយអត់មានថ្នាំព្យាបាលទេពូ?

ហៀងៈ ឈឺវាចេះតែឈឺហើយ គ្មានថ្នាំពេទ្យពីណាមក មានតែដូចជាកូនខ្ញុំអាយុ៣ឆ្នាំអញ្ចឹង ទៅវាឈឺកើតអ៊ុតស្វាយអញ្ចឹងទៅ សុំគេគេចោទយើងថា យើងជាម្ដាយជាឪពុកមិនធ្វើការនៅមើលកូនសក្តិអារម្មណ៍ តែដល់គេមកមើលឃើញដាក់ស្ដែងរលួយពេញខ្លួនណា៎ កូនខ្ញុំដាក់ស្ដែងរលួយក្រាលស្លឹកចេកដេក វាកើតអ៊ុតស្វាយ កើតអុតណា ប្រធានកងគេមកជួយ តែមានប្រធានកងខ្លះទៅរាយការណ៍កងធំថាសក្តិអា-រម្មណ៍ គេប្រុងយកខ្ញុំទៅសម្លាប់ទៀតណា៎ ខ្ញុំនិង កុំអីមិនរស់បាននៅសព្វថ្ងៃនេះទេ

សុជាតិៈ ឥឡូវកូននិងនៅរស់ទេ?

ហៀងៈ កូនទៅរស់ ស្នាមរលួយអីប៉ុនៗនិងហេះ ស្នាមរលួយពេញខ្លួនទាំងអស់ គេចោទយើងថាយើងនេះធ្លាប់ស្រណុកធ្លាប់អីអញ្ចឹងទៅណា គេបែងចែកហើយណា៎ សក្តិអារម្មណ៍អញ្ចឹងទៅ គេចោទយើងទាំងអស់

សុជាតិៈ ចុះពូអ្នកដទៃពេលគេឈឺអីយ៉ាងម៉ិចដែរ?

ហៀងៈ ដូចតែគ្នា តាមកងអ្នកពេញសិទ្ធទៅគេមានកន្លែងគេយកទៅពេទ្យអីអញ្ចឹងទៅ គេមានអីព្យាបាលអញ្ចឹងទៅ រឺគេមានអ្នកកោសខ្យល់អីព្យាបាលអញ្ចឹងទៅណា ដល់យើងទោះជាអ្នកឯងឈឺបាយវាមិនឲ្យយកមកផង អ្នកឯងហូបកើតហូបទៅ អត់ៗ ទៅទុកឲ្យយើងងាប់ទៅ គេថាងាប់ចោល១-២ក៏វា ទុកក៏មិនចំរើន អានិងហើយរបបប៉ុលពត

សុជាតិៈ ចុះពូមានដែលលឺដំណឹងថានៅកន្លែងផ្សេងមានគេឈឺអត់មានថ្នាំព្យាបាលហើយដេកចាំតែស្លាប់ទៅ មានដែលលឺដំណឹងអីអញ្ចឹងទេ?

ហៀងៈ មាន

សុជាតិៈ ពូលឺអញ្ចឹងដែរ?

ហៀងៈ បាទ មាន

សុជាតិៈ នៅឯណាពូ?

ហៀង៖ អានិងដូចថា អ្នកស្លាប់នៅក្នុងកងរបស់ខ្ញុំ ឃើញគេស្លាប់មួយអានិងវាច្របូកច្របល់ មិនដឹងអ្នកណាអីអ្នកណា ខ្ញុំភ្លេចហើយណា៎ តាំងពីឆ្នាំនិងមក អ្នកឈឺអត់មានថ្នាំអី ស្លាប់ចោលនៅនិងទៅ

សុជាតិ៖ អត់ដែលមានថ្នាំអីលែបទេកាលនិង?

ហៀង៖ អត់ទេ បើមានថ្នាំមានតែអាខ្មៅៗនិង ជូនគេឲ្យជូនគេមិនឲ្យ ជូនពេទ្យគេមិនមើល យើងផង ថាឲ្យយើងស្ដីឲ្យយើងក៏មានដែរ ហើយជូនកាលគេយកទៅដាក់ពេទ្យរបស់គេ ពេទ្យមូលដ្ឋានរបស់គេ ពេទ្យថ្នាក់ឃុំរបស់គេ គេអត់មានយកចិត្តទុកដាក់យើងទេ តាមប្រភេទណា គេថាតាមវណ្ណៈណា៎

សុជាតិ៖ បាទ អ្នកមូលដ្ឋាននិងពូនៅជាមួយគ្នាអត់ទេពេលដែលសំរាកនៅពេទ្យ?

ហៀង៖ អត់ទេ នៅផ្សេងគ្នា មិននៅជាមួយគ្នាទេ គេមិនចង់និយាយរកយើងផង គេខ្លាចពាក់ព័ន្ធជាមូលដ្ឋាននិងក៏ដោយ ជាអ្នកនៅស្រុកភូមិជាមួយគ្នា គេមិនហ៊ានមាត់ជាមួយយើងទេ គេថាខ្លាចយើងពាក់ព័ន្ធជាមួយគេណា៎

សុជាតិ៖ បាទ ពូមានដែលគេចាប់ឃុំឃាំងទេពូ កាលពីសម័យនិង?

ហៀង៖ ខ្ញុំគេអត់ដែលឃុំឃាំងទេ តែដូចតែជាប់ដែរ គេមិនឲ្យយើងដើរ

សុជាតិ៖ តែអត់ដែលជាប់គុកអីទេហេះ?

ហៀង៖ អត់ទេ

សុជាតិ៖ ពូមានដែលឃើញគេជាប់គុកតែម្ដងទេ?

ហៀង៖ ខ្ញុំឃើញ ឃើញបង

សុជាតិ៖ គេឲ្យពូទៅកន្លែងគុកដែរ?

ហៀង៖ ទៅ....គុកគេនៅឆ្ងាយអីអញ្ចឹងទៅ ហើយគុកគេនៅឆ្ងាយអញ្ចឹងទៅ គេស្រលាញ់យើងគេប្រាប់យើងថា វេទនាណាស់ គេប្រាប់យើងថាវេទនាខ្លាំងណាស់

សុជាតិ៖ អញ្ចឹងពូអត់ដែលឃើញគេជាប់តែម្ដងទេ តែធ្លាប់ឃើញហេះ?

ហៀង៖ បាទ អត់ដែលធ្លាប់ឃើញទេ តែធ្លាប់លឺ រឿងឃើញដាក់ស្ដែងគេអត់ឲ្យយើងឃើញទេ

សុជាតិ៖ ចុះពូរឿងជំរកស្នាក់នៅផ្ទះសំបែងអីមានដែលខូះខាតទេ កាលពីជំនាន់និង?

ហៀង៖ ខ្ញុំគេទៃឡុងអស់ហើយនិងផ្ទះនិង គ្រាន់តែគេយកម្ដាយ យកឪពុកអីទៅ ផ្ទះនិងគេដាក់ឡៃឡុងតែម្ដង ដកទ្រព្យសម្បត្តិទាំងអស់ នៅតែខ្លួនទេ ចេញដោយខ្លួនទទេ

សុជាតិ៖ ចុះពូចេញទៅភូមិសំបួរនិង ពូនៅយ៉ាងម៉ិច ខ្ទម រឺ ផ្ទះ?

ហៀងៈ ខ្ញុម ផ្ទះនិងយើងអាចសុំគេរុះទៅនៅនោះទៅ ដល់ពេលត្រលប់មកវិញដេញយើងចេញហើយនិងណា៎ ដេញយើងចេញគេថាអត់មាន.......

សុជាតិៈ នៅម្តុំៗគ្នាច្រើនអញ្ចឹងទៅហេះ?

ហៀងៈ បាទ នៅច្រើនគ្នា

សុជាតិៈ ចុះនៅកន្លែងផ្សេងគេពិបាកនៅ រឺស្រួលអីដែរ?

ហៀងៈ កន្លែងផ្សេងដូចតែគ្នា អត់មានខុសគ្នាទេ

សុជាតិៈ ពូមានដែលត្រូវរបួសអីធ្ងន់ធ្ងរទេ កាលពីជំនាន់ប៉ុលពតនិង?

ហៀងៈ អត់ទេ

សុជាតិៈ ចុះពូមានដែលឃើញគេត្រូវរបួសទេ ជីកៗអញ្ចឹងទៅ កាប់ត្រូវគ្រាប់រឺមុតចបគ្នាអីពូមានដែលឃើញទេ?

ហៀងៈ អត់ទេ ប៉ុលពតអត់ទេ

សុជាតិៈ ពូមានដែលលឺដំណឹងទៅកន្លែងផ្សេងគេត្រូវរបួសអញ្ចឹងទេ?

ហៀងៈ អត់

សុជាតិៈ ចុះពូមានដែលជួបប្រយុទ្ធតទល់គ្នាទេ ឧទាហរណ៍ថាខាងណេះខាងខ្មែរក្រហម ខាងណេះខាងវៀតណាមហើយពូនៅកណ្តាលអញ្ចឹងណា៎ ពូមានដែលប្រទះអញ្ចឹងទេពូ?

ហៀងៈ អត់ទេ

សុជាតិៈ ពូមានដែលឃើញគេប្រយុទ្ធគ្នាទេ?

ហៀងៈ អត់

សុជាតិៈ ចុះមានលឺដំណឹងថាគេប្រយុទ្ធគ្នាអីដែរពូហេះ?

ហៀងៈ លឺ តែអត់ដែលជួបប្រទះ អត់ដែលឃើញទេ

សុជាតិៈ ពូកាលពីជំនាន់ប៉ុលពតនិង គេមានដែលអប់រំពូឲ្យផ្លាស់ប្តូរគំនិតអីដែរអត់ទេ?

ហៀងៈ គេអប់រំ ហើយគេប្រុងយកទៅសម្លាប់ទៀតផង គេអប់រំនៅពេលយប់ ពីម៉ោង៦ដល់ម៉ោង២យប់

សុជាតិៈ គេអប់រំពូតែម្នាក់ឯងទេហេះ?

ហៀងៈ បាទ អប់រំតែឯងទេ

សុជាតិៈ គេអប់រំថាមុិចកាលនិងពូ?

ហៀងៈ គេអប់រំថា យើងធ្វើការប្រសេចប្រសាចនិងការងារ មិនយកចិត្តទុកដាក់និងការងារភ្ជួរមិនត្រូវគន្លង ភ្ជួរអញ្ចឹងទៅវាចគេថាយើង បុកគុកបាក់នង្គ័លក៏គេថាយើង គេ

អប់រំយើងខ្ញុំគេប្រុងយកទៅសម្លាប់ហើយតើ គេគូសបិចប្រហមហើយតើ គេប្រាប់ គេប្រាប់ខ្ញុំថា ខ្ញុំគេប្រុងយកទៅហើយតែគេឃើញខ្ញុំស្រលាញ់ការងារយ៉ាងស្មោះ ត្រង់ ខ្ញុំបំភ្លឺខ្លះទៅ ក៏ស្ងាត់ទៅ

សុជាតិៈ ហើយអ្នកអប់រំពូនិងប៉ុន្មាននាក់កាលនិង?

ហៀងៈ អប់រំនៅនេះមួយ

សុជាតិៈ ឥឡូវនៅនិង?

ហៀងៈ បាទ

សុជាតិៈ គាត់ឈ្មោះអី?

ហៀងៈ ឈ្មោះ មើគ នៅភូមិតាសូរ

សុជាតិៈ គាត់និងយ៉ាងម៉ិច?

ហៀងៈ អានិង អប់រំខ្ញុំថាខ្ញុំតែម្តង ថាខ្ញុំតែម្តង

សុជាតិៈ អូ! គាត់នៅភូមិអីពូ?

ហៀងៈ ភូមិតាសូ ប្រធានកង ត្រួត៤ភូមិហើយ

សុជាតិៈ អូ! គាត់នៅរស់តែម្តងណ៎

ហៀងៈ បាទ នៅរស់ ហើយឥឡូវនិងអាចារ្យទៀត ពីមុនអាចារ្យតែកាលពីមុនធ្វើបាបខ្ញុំដែរ និង សំដីដាក់ខ្ញុំអប់រំខ្ញុំប្រុងយកខ្ញុំទៅវៃចោលណោះ ខ្ញុំមិនភ្លេចទេ តែខ្ញុំចេះតែអស់ កំហឹងអស់អីទៅ អស់សងសឹកហើយ ខ្ញុំស្រវាតែសុខទេចំណាស់ខ្ញុំហើយ តែខ្ញុំមិន ភ្លេចទេ ធ្វើបាបខ្ញុំកន្លែងណាក៏ខ្ញុំដឹងដែរ

សុជាតិៈ ចុះពូមានដែលប្រជុំគ្នាច្រើនឲ្យស្អប់គំនិតចាស់គិរិលអីទេ?

ហៀងៈ ប្រជុំច្រើនប្រជុំយប់ ឡើងពីធ្វើការងារអញ្ជឹងទៅបាយហើយម៉ោង៧-៨គេចាប់ ផ្តើមប្រជុំ ម៉ោង៣និងគឺឡើងធ្វើការ

សុជាតិៈ អូ! សំរាកបានមួយភ្លេតពូ?

ហៀងៈ ថាខ្ញុំរឿងវេទនានិង គឺវេទនាណាស់ជំនាន់និង

សុជាតិៈ ចុះពូមានដែលលឹកន្លែងផ្សេងគេអប់រំឲ្យកែគំនិតអីដែរហេះ?

ហៀងៈ ដូចគ្នា

សុជាតិៈ ពូកាលពីជំនាន់ខ្មែរក្រហម ពូមានដែលខ្មែរក្រហមចាប់ពូទៅដាក់កន្លែងណាឆ្ងាយពីអ្នក ដទៃទេ ឲ្យនៅដាច់តែឯងតែម្តង?

ហៀងៈ មានតែគេកែន គេកែនយើងឲ្យចូលប្រមូលដុំអីនៅភ្នំលិចអញ្ជឹងទៅណ៎

សុជាតិៈ	គ្នាច្រើនរឺតិច?

ហៀងៈ	ច្រើន

សុជាតិៈ	អូ! រឿងគេយកពូទៅដាក់នៅកន្លែងណាតែឯងអញ្ចឹងអត់មានទេហេះ?

ហៀងៈ	អត់ទេ

សុជាតិៈ	ចុះពូមានដែលឃើញនរណាម្នាក់គេយកទៅដាក់កន្លែងណាតែឯងកុំឲ្យឡូកឡំជាមួយគេទេ?

ហៀងៈ	អត់ទេ មានតែក្នុងចំណោម១០-២០នាក់អញ្ចឹងទៅ គេដាក់ម្ដុំអញ្ចឹងទៅ គេដាក់ម្ដុំ អត់ដែលតែឯងទេ

សុជាតិៈ	អត់មានតែឯងទេហេះ?

ហៀងៈ	អត់មានតែឯងទេ

សុជាតិៈ	ចុះពូ ដែលជួបហេតុការណ៍បិះតែនិងស្លាប់ខ្លួនទេពូ?

ហៀងៈ	ហេតុការណ៍និងដូចខ្ញុំបានជិរាបអញ្ចឹង គេថាយើងការងាររសន្រ្ទន់ យើងយកទៅភ្ជួរ បុកគល់ យើងភ្ជួរទៅគន្លងមិនត្រង់គេថាយើង ក្នុងការពាក់ព័ន្ធគេចេះតែថាទៅ ពីចំណុចមួយទៅចំណុចមួយ គេចេះតែថាទៅ

សុជាតិៈ	ចុះពូមានដែលឃើញអ្នកដទៃបិះតែគេយកទៅសម្លាប់ទេ ដូចជាមិត្តភក្រពូអីអញ្ចឹងណា?

ហៀងៈ	គេប្រាប់ តែគេប្រាប់ក្រោយពី៧៩មកហើយទេ

សុជាតិៈ	ពូមានដែលឃើញអ្នកធ្វើការជាមួយពូ គេរៀបនិងយកទៅសម្លាប់ហើយតែគេអត់យកទៅវិញណា៎ ពូមានដែលឃើញអញ្ចឹងទេ?

ហៀងៈ	មានដែរ គេរៀបយក២-៣នាក់ចាស់ៗដូចជាចាប់បងជីដូនមួយខ្ញុំចាស់ៗ គេរៀបយកទៅដែរ អានិងសុទ្ធតែបិចក្រហម តែបិចក្រហមគេចូលហើយ តែបានទព្វវៀតណាមចូលមក

សុជាតិៈ	អូ!

ហៀងៈ	ខ្ញុំច្រើនរឿងណាស់គេប្រុងតែនិងយកទៅនិង រឿងច្រើនណាស់

សុជាតិៈ	ពូខុសច្រើនកាលនិង?

ហៀងៈ	បាទ ខ្ញុំខុស ខ្ញុំយកគោទៅ លែងគោឲ្យស៊ីអញ្ចឹងទៅ គោជល់គៀងទៅ គេចោទយើងច្រើនណាស់ខ្ញុំ ទៅភ្ជួរនៅព្រៃលិចបុកគល់ទៅ គេខាតការងារគេគេថាយើង

សុជាតិៈ	កាលនិងមានបាក់នង្គ័លទេ?

ហៀង៖ បាក់ តែបុកបាក់ហើយនឹង្គ័ល ហើយគោកាលនិង អាប្រធានកងភ្ជួរនៅខាងក្រោយ យើង ហើយយើងភ្ជួរពីមុខ គេដេញយើង ហើយយើងចេះតែវ៉ៃគោទៅមុខទៀត ទៅ បុកគល់វាបាក់ ដល់បាក់គេថាយើងនេះសត្តិអារម្មណ៍ ប៉ុលពតគេនិយាយតែពី រឿងសត្តិអារម្មណ៍និងតែម្តង

សុជាតិ៖ បាទ

ហៀង៖ ប្រធានកងដែលគេប្រុងតែយកខ្ញុំនិង នៅសព្វថ្ងៃដែរនិង ថាឲ្យខ្ញុំ ទៅសួរគាត់មើល ថាតើរបៀបគ្រប់គ្រង ប៉ុលពតនិងយ៉ាងម៉ិច?

សុជាតិ៖ អញ្ចឹងពូ ពេលដែលជំនាន់ប៉ុលពតនិងពូធ្វើការជួបជុំបងប្អូន គ្រួសារអីដែរអត់ទេ?

ហៀង៖ ខ្ញុំបែក ទាំងអស់ គ្រួសារខ្ញុំទៅខាងកងស្រី ខ្ញុំកងប្រុសអញ្ចឹងទៅ បាទ

សុជាតិ៖ ចុះបងប្អូនពូ?

ហៀង៖ បងប្អូនខ្ញុំ បងខ្ញុំគេយកទៅដាក់គុកទៀតទៅ បងស្រីខ្ញុំគេដាក់គុកដែរនិង

សុជាតិ៖ អូ! គេដាក់គុកដែរតែរួចមកវិញហេះ?

ហៀង៖ បាទថាខ្ញុំអស់រលីងតែម្តង គេឡៃឡុងតែម្តង ផ្ទះខ្ញុំគេដកហូតទាំងអស់ ផ្ទះនិងគេមិន នៅជង

សុជាតិ៖ ចុះពេលគេបំបែកនិងគេបង្ខំពូដែរអត់ទេពូ?

ហៀង៖ គេអត់មានបង្ខំអីទេ តែគេថាគេហាមយើងមិនឲ្យដើរជាបក្សពួកអី ដើរគេមិនឲ្យ យើងដើរជំនុំ ដើរអង្គុយអីអត់ទេ

សុជាតិ៖ គេអត់បង្ខំទេ តែបើអត់ទៅ.......?

ហៀង៖ អើ អានិងគេតាមដាន

សុជាតិ៖ ចុះអ្នកដែលនៅធ្វើការជាមួយពូ ពូមានដែលឃើញគេបង្ខំឲ្យចេញពីគ្រួសារដែរទេ?

ហៀង៖ អានិងគេអ្នកស្រលាញ់យើងនិង ខ្លះគេមិនស្រលាញ់គេប្រាប់យើងទៅ យើងពេល និងយើងអត់ហ៊ាននិយាយតែម្តង

សុជាតិ៖ តែគេបំបែកចេញពីគ្រួសារដែរហេះ?

ហៀង៖ បាទ បំបែក បំបែកចេញពីគ្រួសារដែរ

សុជាតិ៖ និយាយអញ្ចឹងពូមានដែលលឺគេនៅកន្លែងផ្សេងគេបំបែកចេញពីគ្រួសារអញ្ចឹងទេ?

ហៀង៖ អត់ទេ បែកទាំងអស់ គេអត់ឲ្យនៅធ្វើការជុំគ្នាទេ គ្រួសារដោយគ្រួសារគេបំបែក ទាំងអស់

សុជាតិ៖ ពូមានដែលឃើញគេសម្លាប់មនុស្សទេកាលពីជំនាន់ប៉ុលពតនិង?

ហៀង៖ អត់ទេគេអត់ឲ្យចូលទៅ គេអត់ឲ្យយើងចូលទៅកន្លែងគេសម្លាប់ទេ កន្លែងមន្ទីរក៏គេអត់ឲ្យយើងទៅ

សុជាតិ៖ អញ្ចឹងពូគ្រាន់តែដឹងថាគេសម្លាប់ខ្លួនតែអត់ដឹងថាគេសម្លាប់ទេ?

ហៀង៖ លឺដែរគេថាសម្លាប់ដែរអត់ដែលឃើញទេ រឿងសម្លាប់នៅឯណាគេអត់ប្រាប់ទេ

សុជាតិ៖ ចុះពូមានដែលឃើញមនុស្សស្លាប់ខុសពីធម្មតាទេ ដូចជាឈឺស្លាប់អី?

ហៀង៖ បាទ ឈឺស្លាប់មាន នៅតាមកងតាមអី ស្លាប់ដោយគ្មានថ្នាំអីនិង

សុជាតិ៖ ស្លាប់និងចាស់រឺក្មេង?

ហៀង៖ ស្រករៗគ្នាតាមកង ធ្វើពលកម្មខ្លះខាតហើយ ធ្វើពលកម្មហើយខ្លះជីវជាតិណាបាយមិនគ្រប់គ្រាន់ហើយខ្លះទៅ

សុជាតិ៖ តែមិនមែនសម្លាប់ទេ ស្លាប់ដោយសារអត់បាយ

ហៀង៖ បាទ ដោយសារអត់បាយ សម្លាប់គេមិនឲ្យយើងដឹងទេ

សុជាតិ៖ ចុះពេលដែលកំពុងសែនដីៗ ស្លាប់ដួលព្រួសអញ្ចឹងអីមានទេ?

ហៀង៖ មាន ដូចជាខ្យល់អញ្ចឹងទៅ ដូចគ្នាឈឺអញ្ចឹងទៅ ហើយគ្នាធ្វើការគេជំរុញខ្យល់អញ្ចឹងទៅ.........អានិងជំងឺដែលវាឈឺអញ្ចឹងទៅគេជំរុញទៅណា ហើយអាជំរុញនិងវាតាមប្រភេទវណ្ណៈមន្ទីលអញ្ចឹងទៅគេជំរុញយើង

សុជាតិ៖ ពូមានដែលលឺដំណឹងថានៅកន្លែងផ្សេងមានសាចញាត្តិនរណាម្នាក់ស្លាប់អញ្ចឹងទេ?

ហៀង៖ អត់ទេ ខ្ញុំដឹងតែនៅតាមកងខ្ញុំតែម្តង តាមកងនានាគេមិនឲ្យយើងដឹង

សុជាតិ៖ ពូពីជំនាន់ខ្មែរក្រហមនិងពូមានដឹងដំណឹងថាបងប្អូនឯងសម្លាប់បងប្អូនឯង កូនសម្លាប់អីទេពូ ដែលលឺដំណឹងអញ្ចឹងទេពីជំនាន់ប៉ុលពតនិង?

ហៀង៖ ដូចជាកូនសម្លាប់ឪពុក ឪពុកសម្លាប់កូនអញ្ចឹងហេះ?

សុជាតិ៖ បាទ

ហៀង៖ ហ៊ឺ ពិបាកណាស់ខ្ញុំ ពិបាកបំភ្លឺប្រាប់ដែរព្រោះដូចខ្ញុំជំរាបអញ្ចឹងថា គេមិនឲ្យយើង ដឹងដូចខ្ញុំបានជំរាបអញ្ចឹងថាខ្ញុំជាវណ្ណៈនិងសូម្បីតែទីរបស់គេ សូម្បីតែផ្ទះរបស់ខ្ញុំនេះក៏គេមិនឲ្យយើងមកបៀតផង គេមិនឲ្យយើងដឹងដែរ

សុជាតិ៖ អញ្ចឹងសម័យនិងពូនៅនិងភូមិសំប៊ូរនិងរហូតតែម្តង?

ហៀង៖ បាទ គេមិនឲ្យយើងនៅនេះផង ផ្ទះនេះគេឡៃឡុងអស់ហើយ ផ្ទះសម្បត្តិគេយកទាំងអស់

សុជាតិ៖ អត់ដែលមានឱកាសមកលែងម្តងម្កាលអីទេហេះ?

ហៀង៖ អត់ទេ

សុជាតិ៖ ពូមានដែលវង្វេងវីទៅភូមិណាផ្សេងទៀតហើយអត់ស្គាល់កន្លែងនិងជាកន្លែងអីទេពូ? មានដែលគេចាប់ដាក់កន្លែងណាមួយ ហើយអត់ដឹងថាកន្លែងនិងជាកន្លែងអីណា៎?

ហៀង៖ មានដូចថាគេចេញធ្វើការចេញយប់អញ្ចឹងទៅ គេយកដាក់គេច្រើនទៅលិចត្រពាំងធំ អីវាវង្វេងដែរយប់

សុជាតិ៖ គេយកពូទៅដែរហេះ?

ហៀង៖ គេដាក់នៅកន្លែងតាមកងគេ គេបញ្ជូនយើងទៅពេលយប់ ដូចថាគេចេញយប់អញ្ចឹងទៅមានបន្ទីរមានចបអីគេយកចេញពេលយប់អត់មានចេញពេលថ្ងៃទេ ពេលម៉ោង ១-២ រឺម៉ោង១១អីគេថា ឥឡូវកម្លាំងយើងត្រូវចេញគេឲ្យចេញ

សុជាតិ៖ គេអត់មានប្រាប់ថាទៅណាទេហេះ?

ហៀង៖ អត់ទេ ស្នាក់ការគេគឺនៅក្នុងព្រៃបោះទីតាំងកន្លែងនិងយើងអត់ដឹង

សុជាតិ៖ ពូស្គាល់កន្លែងនិងទេ?

ហៀង៖ ស្គាល់ខ្ញុំ ដូចជានៅព្រៃព្រាលអីនេះ ដល់ឥឡូវយើងស្គាល់យើងធ្លាប់ដើរអញ្ចឹងទៅ

សុជាតិ៖ ទៅដំបូងអត់ដឹងថាកន្លែងនិងជាកន្លែងអីទេអញ្ចឹង ទាល់តែភ្លឺទើបដឹង?

ហៀង៖ បាទ ភ្លឺហើយនិងក៏ខ្ញុំមិនដឹងដែរ ទើបតែសម័យឥឡូវនេះទេទើបដឹង ដឹងធ្លាប់ដើរអញ្ចឹងទៅ អានេះភូមិនេះ អានេះភូមិនោះ

សុជាតិ៖ អញ្ចឹងបានន័យថាកាលពីមុនប៉ុលពតពូអត់ដែលទៅលេងកន្លែងនោះទេអញ្ចឹង?

ហៀង៖ អត់ទេ អត់ដែលទេ

សុជាតិ៖ ពូទៅគ្នាច្រើនទេ?

ហៀង៖ តាមកងដូចជា៤០-៥០នាក់

សុជាតិ៖ ហើយអ្នកដទៃអត់មាននរណាម្នាក់ស្គាល់អញ្ចឹងដែរហេះពូ?

ហៀង៖ អត់មាននរណាម្នាក់ស្គាល់ ហើយអត់មានដើរជជុំគ្នាអត់ទេ អត់មានជជុំគ្នារឿងអីទេ

សុជាតិ៖ ចុះពូមានដែលលឺនៅកន្លែងផ្សេង គេឲ្យទៅកងណាផ្សេងទៀតហើយអត់ស្គាល់អញ្ចឹងទេ?

ហៀង៖ ដូចតែគ្នា អានិងគេ១៧អញ្ចឹងទៅ អ្នកមូលដ្ឋានក៏ដោយ អ្នកប្រភេទណាក៏ដោយគ្មានដែលស្គាល់អីទេ យើងអញ្ចឹង គេដាក់ឲ្យនៅភូមិនេះអីទៅ ហើយទៅកងនេះអញ្ចឹង ទៅយើងអត់មានស្គាល់អីទេ គេចេញយប់មិនដឹងជាកន្លែងណាអីកន្លែងណាទេ

សុជាតិ៖ ពូមានដែលធ្វើខុសអីគេធ្វើទារុណកម្មទេពូ?

ហៀងៈ អត់ទេ ដែលតែស្តី ដែលតែថា អានេះស្តីតែម្តង ហើយគេត្រៀមលក្ខណៈរបស់តែម្តងពេលដែលខ្ញុំភ្ជួរដីបុកគល់វៀចណា គេគូសប៊ិចយើង គេអប់រំយើងហើយគេគូសប៊ិចយើងហើយខ្ញុំគុណបុណ្យកងទព្វវៀតណាមចូលកុំអីខ្ញុំស្លាប់ហើយ ប៉ិះនិងស្លាប់តែម្តង

ប្រពន្ធហៀងៈ ចុះខ្ញុំកូនឈឺប្រហែលជា៦ខែ អាវាអ៊ុតស្វាយនិង ដល់ហើយឪវាភ្ជួរអាខុសគន្លងគេនេះ គេតាមដានទៀតកុំបានវៀតណាមចូលនិងកុំអីទៅដែរនិង

ហៀងៈ ទៅទាំងអស់

សុជាតិៈ បាទ

ហៀងៈ ប្រវត្តិឯងវារដ្ឋការចាស់ វានេះផងនោះផង ផាកទៅឪពុកខ្ញុំជាប់គុក ផាកទៅម្តាយខ្ញុំគេសម្លាប់ ផាកទៅបងថ្លៃគេសម្លាប់ ផាកទៅឪពុកម្តាយក្មេករដ្ឋការព្រៃក្ខុច អតីត ណា៎ គេថាទាហានចាស់ គេដាក់ព្រៃក្ខុចនិង២០៨ណា

សុជាតិៈ ឪពុកពូនិងគេដោះលែងពីគុកឆ្នាំណាដែរពូ?

ហៀងៈ ឆ្នាំ ៧៧និង

សុជាតិៈ ជាប់គុកបានប៉ុន្មានឆ្នាំពូ?

ហៀងៈ ជាប់គុកបានប្រហែលជា៦ខែគេដោះលែងមកវិញឪពុកខ្ញុំមួយ បងខ្ញុំមួយ បងខ្ញុំថានៅភ្នំដីនិង លែង២តែសម្លាប់២

សុជាតិៈ អញ្ចឹងឪពុកពូគាត់ស្លាប់ឆ្នាំណាដែរ?

ហៀងៈ ទើបតែស្លាប់ឥឡូវៗនិង គាត់មានជំងឺដោយគេធ្វើបាបគាត់ផង ចុះឪពុកខ្ញុំកាលនិង

សុជាតិៈ កាលពីជំនាន់និងស្អីខ្លះទៅដែលប៉ុលពតចាត់ទុកថាខុសពូ?

ហៀងៈ ដូចខ្ញុំបានជំរាបអញ្ចឹង គេបែងចែកវណ្ណៈ រឺមួយគាត់ចាស់អញ្ចឹងគេបែងចែកគាត់ជាពលកម្មតែម្តងហើយតាមតែគេចោទណា៎ ពេលគេយកយើងគេយកទៅពេលយប់អត់ដឹង បែកទាំងអស់ បង៤នាក់បែកទាំង៤ អត់មានឲ្យនៅប្រមូលផ្តុំគ្នាទេ បែកទាំង៤

សុជាតិៈ ពូមានដែលឃើញគេធ្វើទារុណកម្មនរណាម្នាក់ផ្សេងទៀតទេ?

ហៀងៈ អត់ទេ គេមិនឲ្យដឹងទេ អត់ឲ្យឃើញទៀត វណ្ណៈយើងអញ្ចឹងគេមិនឲ្យយើងដឹងទេ សូម្បីតែពីភូមិនិងទៅភូមិលិចនិងក៏គេមិនឲ្យយើងដឹងដែរ សូម្បីតែមន្ទីរស្នាក់ការឃុំគេក៏គេមិនឲ្យយើងទៅបៀតផង

សុជាតិៈ អញ្ចឹងក្រៅពីពូភ្ជួរបាក់នង្គ័លហើយពូភ័យរន្ធត់ណាស់កាលនិង ហើយពូមានដែលជួបហេតុការណ៍អីផ្សេងទៀតទេ?

ហៀងៈ អានិងតាមប្រភេទ កម្រដែរ ដូចថាពាក់ព័ន្ធគេយកឪពុកម្តាយអញ្ចឹងទៅ តាមគេយកសម្លាប់អញ្ចឹងទៅគេតាមនិងដែរទៅដូចគ្នា តែអ្នកណាគេពេញសិទ្ធវណ្ណៈគេអ្នកល្អអញ្ចឹងទៅ គ្មានពាក់ព័ន្ធអញ្ចឹងទៅ ទៅតាមនិងទៀតអញ្ចឹងទៅ ជាពិសេសពេលយប់និងមានសេនាជនឈ្លបគេមកតាមដានយើងទៀតហើយ យប់ឡើងឈ្លបលូនក្រោមគ្រែអីណោះ

សុជាតិៈ ពេលគេលូនក្រោមគេនិង ពូដឹងដែររឺមិនដឹងទេ?

ហៀងៈ ដឹងដែរតែនរណាហ៊ានមាត់អីមួយម៉ាត់ គេយកយើង អញ្ចឹងយើងតមសម្ងំថាមិនមាត់តែម្តង អញ្ចឹងតមសម្ងំថាមិនមាត់មិនដឹងធ្វើតែការងារយើង ការងារយើងធ្វើទាញតែបង្គីហើយនិងចបនិងមកវែកទៅ ឈើក៏ចេះតែទ្រាំទៅ

សុជាតិៈ ពេលដែលពូនឹកឃើញដល់សម័យប៉ុលពតនិង តើពូឈឺចាប់អីជាងគេបំផុត?

ហៀងៈ ពេលដែលនឹកឃើញដល់សម័យប៉ុលពតគឺគេធ្វើបាបខ្ញុំដោយបង្អត់ទាំងអស់ ហើយនិងការយកបងប្អូនខ្ញុំហើយនិងឪពុកខ្ញុំទៅដាក់គុកអញ្ចឹងទៅខ្ញុំមានការឈឺចាប់ណាស់ តែខ្ញុំមានតែការឈឺចាប់ទេ ការគុំគួន ដូចជាអ្នកនៅរស់ អ្នកធ្វើបាបខ្ញុំក៏មិនមានការគុំគួនដែរ

សុជាតិៈ ម្តាយពូគេឃុំនៅឯណា?

ហៀងៈ យកទៅពីនិងទៅដាក់នៅភូមិក្របីព្រៃ តែគេយកទៅសម្លាប់មិនដឹងជាសម្លាប់នៅឯណាទេ គេមិនឲ្យយើងដឹងទេ បែបក្រាំងតាចាន់ដែរ

សុជាតិៈ ធ្វើម៉ិចបានជាពូដឹងថាគេសម្លាប់?

ហៀងៈ គេប្រាប់

សុជាតិៈ នរណាគេប្រាប់?

ហៀងៈ អ្នកនៅជាមូលដ្ឋានអីនិង គេថាយកទៅសម្លាប់ ខ្ញុំសួរថាគេយកទៅសម្លាប់នៅឯណាគេមិនប្រាប់យើង តែដឹងតែគេយកទៅសម្លាប់ហើយ

សុជាតិៈ ពូដឹងថានឹងឆ្នាំណាដែរ?

ហៀងៈ ប្រហែលជា៧៦ - ៧៧ដែរ

សុជាតិៈ មុនវៀតណាមចូលមកយូរទេ?

ហៀងៈ ហ៊ឺ មុនវៀតណាមយូរណាស់

សុជាតិៈ ពូតាំងពីតូចមកដល់ឥឡូវពូមានដែលលង់ទឹកទេ?

ហៀងៈ លង់ទឹក?

សុជាតិៈ បាទ

ហៀងៈ អត់ទេ

សុជាតិៈ ពូមានដែលចេះតែថប់ៗដង្ហើមទេ?

ហៀងៈ អត់ទេ តែមានជំងឺក្រពះ

សុជាតិៈ អញ្ចឹងពូអត់ដែលថប់ដង្ហើមទេហេះ?

ហៀងៈ អត់ទេ

សុជាតិៈ ពូមានដែលគេវាយត្រូវក្បាល រឺបោកទង្គិចក្បាលដែរទេ?

ហៀងៈ អត់ទេ បើគ្រួសារខ្ញុំវះ២ដង

សុជាតិៈ ពូដែលសន្លប់បាត់បង់ស្មារតីដែរទេ?

ហៀងៈ អត់ទេ មានតែជំងឺក្រពះតែប៉ុណ្ណឹង

សុជាតិៈ ពូ ខ្ញុំចង់ដឹងពីអារម្មណរបស់ពូក្នុងរវាង១អាទិតកន្លងទៅនិង តើពូចេះតែនឹកឃើញដល់ការឈឺចាប់ជារឿយៗដល់សម័យខ្មែរក្រហមដែរទេឥឡូវៗនិង?

ហៀងៈ បាទ នឹកឃើញដែរ នឹកឃើញដល់ភាពវេទនា

សុជាតិៈ ពូចេះតែខស្បារហ៍នឹកឃើញដែរទេពូ?

ហៀងៈ បាទ នឹកឃើញថាគេយកទៅប្រុងនិងសម្លាប់ នឹកឃើញគេគូសត្រៀមលក្ខណៈគេយកទៅសម្លាប់

សុជាតិៈ ឥឡូវនិងពូនៅតែនឹកឃើញអញ្ចឹងដែរ?

ហៀងៈ បាទ នៅតែនឹកឃើញនិង ថ្ងៃណាក៏នៅតែនឹកឃើញអញ្ចឹង មិនភ្លេចទេអារឿងនិង

សុជាតិៈ ពេលដែលពូនឹកឃើញដល់ការឈឺចាប់អញ្ចឹងដូចជានៅថ្មីៗដែរទេ?

ហៀងៈ ថ្មីដែរតែខ្ញុំអត់មានការគុំគួនអីទេ អត់មានចង់សងសឹកអីទេ គ្រាន់តែនឹកឃើញថានឹកឃើញដល់ប៉ុលពតនិងវេទនារបបនិងគឺខ្ញុំដាច់ខាតតែម្តង នឹកឃើញថ្មីថា របបនិងសុខចិត្តជីវិតរបស់ខ្ញុំស្លាប់ក៏ដោយក៏ខ្ញុំមិនលូកដៃរបបនិងទៀតដែរ

សុជាតិៈ ពេលដែលនឹកឃើញរបបនិងទៅពូនឹកឃើញថ្មីៗអញ្ចឹងវានៅតិចៗរឺល្មមទេ?

ហៀងៈ ខ្ញុំនៅភ័យ ដល់អប់រំដល់កូនៗរហូតដល់ចៅខ្ញុំទៀត អប់រំថាកាលនិងឪវេទនាអញ្ចេះអញ្ចោះទៅថាវេទនា ការធ្វើបាប ការគេយកឪពុកគេយកម្តាយទៅ ការបង្អត់បាយអប់រំកូន មិនត្រឹមដល់ប៉ុណ្ណឹងទៅ ដល់ចៅខ្ញុំទៀតឥឡូវនិង របបនិង

សុជាតិៈ ពូចេះតែយលសប្តិឃើញអារឿងអាក្រក់ជារឿយៗដល់សម័យខ្មែរក្រហមទេឥឡូវនិង?

ហៀងៈ អត់ទេ ធម្មតា គ្រាន់តែនឹកឃើញដល់ការលំបាកនិង

សុជាតិៈ ពូមានចេះតែយល់សប្តិឃើញទេ?

ហៀងៈ អារម្មណ៍របស់ខ្ញុំចេះតែនឹកឃើញដែរនិង ជួនណានឹកឃើញថា មិនគួរណាគេយកឪពុកខ្ញុំទៅដាក់គុក យកបងខ្ញុំទៅដាក់គុក បងថ្លៃខ្ញុំគេសម្លាប់ ម្តាយគេយកទៅសម្លាប់ នឹកឃើញខឹងដែរ ខឹងដែរ នឹកឃើញថា បើអ្នកនិងនៅវិញក៏គេមិនរាប់រកដែរ នឹកឃើញនៅថ្មីៗដែរ តែអ្នកនៅសម្លាប់ក៏ងាប់ទៅទៀតដែរ គេថាអំពើអាក្រក់ណាំ ពី៧៩និង យើងរំដោះហើយឆ្នាំ៧៩និងស្លាប់ទៅ អាផាងយើងនេះ

សុជាតិៈ ពូឥឡូវៗនិងពូចេះតែមានអារម្មណ៍មិនរវីរវល់មិនចង់ជួបអ្នកដទៃទេ?

ហៀងៈ ខ្ញុំថាមិនឲ្យចង់ជួនទេអាអំពើនិង

សុជាតិៈ បាទ អំពើនិងយើងមិនចង់ជួបហើយ តែអ្នកជិតខាងពូចេះតែមានអារម្មណ៍មិនចង់រវីរវល់ដែរទេ ចង់នៅតែឯងស្ងាត់ៗអីណា?

ហៀងៈ អត់ទេ ចង់តែជួបជុំបងប្អូន

សុជាតិៈ ពូមានអារម្មណ៍ឆាប់ភ័យខ្លាច ឆាប់ភ្ញាក់ផ្អើលទេឥឡូវនិង?

ហៀងៈ បាទ ខ្ញុំអត់មានខ្លាចទេ

សុជាតិៈ ពេលដែលពូធ្វើការអីមួយពូមានការពិបាកផ្តង់គំនិតគិតទៅលើការងារនិងទេ ដូចថាពេលដែលពូធ្វើការអីមួយ ពូគិតមូលទៅលើការងារនិងដែរ រឺចេះតែបែកឆ្វេង??

ហៀងៈ អានិងវាបែកដែរ នឹកឃើញខុះខាត

សុជាតិៈ អារម្មណ៍អត់មូលនិងមានខ្លាំងទេពូ?

ហៀងៈ ខ្លាំងដែរ ដូចថាកូនវាច្រើនអញ្ចឹងទៅ វាខុះខាតអញ្ចឹងទៅ ចាប់មួយមិននឹងណាំ មិននឹងណាំ អារម្មណ៍វាមិនមូល វាចាប់មិនបានជុតណាំ ខុះខាតវាអញ្ចឹងហើយ

សុជាតិៈ ពូមានការពិបាកក្នុងការទទួលទានដំណេកទេរាល់ថ្ងៃនិង?

ហៀងៈ ដេក ជួនណាវា ដេកមិនសូវបានគ្រប់គ្រាន់ទេ

សុជាតិៈ សំរានមិនសូវបាននិងមានច្រើនទេពូ?

ហៀងៈ ច្រើនដែរ អារម្មណ៍ទី១នឹកឃើញថា គិតទៅក្នុងជីវភាពរស់នៅគ្រួសារ ទី២យើងដេកលក់ទៅមានជនអាក្រក់ដែលគោលបំណងលួច យើងមានអារម្មណ៍២ណាំ

សុជាតិៈ បាទ

ហៀង៖ ដេកពីព្រលប់នឹកឃើញថា ការរស់នៅគ្រួសារមិនដឹងជារស់នៅរបៀបម៉ិច យើងអត់កូនកាន់តែធំ ការស្លៀកពាក់ ទី២នឹកឃើញ ពេលដែកលក់ទៅ ពួកជនអាក្រក់វាមានបំណងនឹកឃើញវេងឆ្ងាយណាស់ ហើយនឹកឃើញទៅទៀតទៅ ដូចថាការខ្វះខាតអញ្ចឹងទៅ នឹកឃើញថាបើនៅក្នុងគ្រួសារមានជំងឺយើងពិបាកអត់លុយព្យាបាល

សុជាតិ៖ ពូគិតរឿងនិងខ្លាំងអញ្ចឹង?

ហៀង៖ បាទ គិត អញ្ចឹងខ្ញុំចេះតែដើរទៅ ដើរក្រឡឹងជុំវិញផ្ទះអញ្ចឹងទៅ ដើរគិតណាំ

សុជាតិ៖ អញ្ចឹងពូចេះតែប្រុងខ្លួនជាប់ជានិច្ចអញ្ចឹងតែម្តងហេះ?

ហៀង៖ បាទ ខ្លាចខ្លាំងណាស់ វាឃើញថា មូលដ្ឋានមកដល់ជនបទអស់និងឃើញថាមានការគុំគួនដែរ ការកាប់សម្លាប់ រឺការប្លន់អញ្ចឹងទៅណា មានការព្រួយបារម្ភ មានឃើញច្រើន ខ្លាចណាស់

សុជាតិ៖ ពូរាល់ថ្ងៃមានការឆាប់ខឹង ឆាប់ផ្ទុះកំហឹងអីទេពូ?

ហៀង៖ ខ្ញុំអត់ទេ អត់ខឹងទេ រាល់ថ្ងៃដូចថាវាខាន់តី ទោះគេជេខ្ញុំក៏អត់មានមាត់ដែរ មិនតមិនអីទេ យកតែសុខជូនគ្រួសារខ្ញុំ

សុជាតិ៖ ចុះពេលដែលសម័យប៉ុលពតគេប្រើពូឲ្យវែកដី ភ្ជួរអីច្រើន ហើយពេលដែលពូមើលឃើញសព្វថ្ងៃពូមានចង់ជៀសវាងដែរទេ?

ហៀង៖ អានិងដូចខ្ញុំជំរាបអញ្ចឹង ខ្ញុំមិនចង់ឲ្យឃើញទេ ហើយខ្ញុំធ្វើបុណ្យរាល់ថ្ងៃជុតធូបមិនចង់ឲ្យជួបនិងរបបនិង

សុជាតិ៖ ពូចង់ជៀសវាងខ្លាំងតែម្តងហេះ?

ហៀង៖ បាទ ខ្លាំង ទីបញ្ចប់មិនចង់ឲ្យជួបតែម្តង អានេះគេហៅថារបបផ្តាច់ការ

សុជាតិ៖ ពូថ្មីៗនិងពូដូចជានឹកឃើញមិនច្បាស់លាស់ដល់ព្រឹត្តិការណ៍ពីជំនាន់ប៉ុលពតនិង?

ហៀង៖ ដូចខ្ញុំជំរាបអញ្ចឹង រឿងគេសម្លាប់ក៏គេមិនឲ្យដឹង ហើយការរស់នៅតាមកងឃើញការស្លាប់ ការរស់នៅដោយវេទនា អានិងខ្ញុំដឹង ដល់ការសម្លាប់ខ្ញុំបានជំរាបប្អូន ហើយខ្ញុំមិនបាបដឹងទេ ពេលដែលសម្លាប់គេមិនឲ្យយើងដឹងទេ ហើយយើងពាក់ព័ន្ធ ផង

សុជាតិ៖ ពូចេះតែមានអារម្មណ៍ថា មិនចាប់អារម្មណ៍និងការងារប្រចាំថ្ងៃទេថ្មីៗនិង?

ហៀង៖ ដូចខ្ញុំជំរៀបអញ្ចឹងខ្ញុំមានការចាប់អារម្មណ៍ណាស់ ការងារប្រចាំថ្ងៃ ការរស់នៅគ្រប់គ្រងជីវភាពណាំ

សុជាតិ៖ ពូចេះតែមានអារម្មណ៍ថា ទៅថ្ងៃមុខទៅដូចជាគ្មានថ្ងៃអនាគតទេពូថ្មីៗទៅ?

ហៀង: ខ្ញុំអត់មានគិតអីទេ ឲ្យតែសុខជួបជុំគ្រួសារតែប៉ុណ្ណឹងទៅ ការរកស៊ីការគ្រប់គ្រង តែប៉ុណ្ណឹងបានហើយ ខ្ញុំអត់មានគិតអីទៅម៉ិចទៀតទេ

សុជាតិ: ពូចង់ជៀសវាងមិនឲ្យគិតឃើញនូវហេតុការណ៍ឈឺចាប់ទេពូ?

ហៀង: មិនចង់ឲ្យជួបហើយមិនចង់ឲ្យនឹកឃើញទេកាលពីសម័យនិង

សុជាតិ: តែចេះតែនឹកឃើញ?

ហៀង: អារម្មណ៍វាចេះតែអញ្ចឹង បែកបាក់ណា៎ ការបែកបាក់គ្រួសារ ដូចថាជីវភាពមិនគ្រប់គ្រាន់ផង ណាមួយកូនវាធំផង ណាមួយនឹកឃើញថាគេយក សម្លាប់ព្រាត់ប្រាស់អញ្ចឹងទៅ វានៅតែនឹកឃើញដែរនិង មិនមែនមិននឹកឃើញណា៎ អញ្ចឹងពេលដែលខ្ញុំសំរានមិនលក់ខ្ញុំដើរឲ្យតែមួយសំទុះទៅ ក៏សំរានទៅ សំរាន និងក៏មិនហ៊ានសូវលក់ដែរ ខ្លាចបារម្ភដែរ ព្រោះយើងនៅឆ្ងាយពីកន្លែងការពារសន្តិសុខវាលំបាកដែរ

សុជាតិ: ចុះពេលដែលពូនឹកឃើញដល់ការឈឺចាប់ពីសម័យខ្មែរក្រហម ពូចេះតែឈឺក្បាលញ័រទ្រូង ភ័យរន្ធត់អីទេពូ?

ហៀង: អានិងដូចខ្ញុំថាអញ្ចឹង កាលពីសម័យនិងវាលំបាកខ្លាំងណាស់ ជួនកាលវាទឹកភ្នែកគិតមែនទែន

សុជាតិ: ដល់ពេលឥឡូវពេលដែលនឹកឃើញអញ្ចឹងវាយ៉ាងម៉ិចដែរ?

ហៀង: នឹកឃើញខឹងដែរ កំហឹងនៅតែខឹង តែយើងជៀសវាងមិនឲ្យមានការគុំគួន ស្អប់

សុជាតិ: អញ្ចឹងអត់ដែលមានប្រតិកម្មដូចថាញ័រដៃ ញ័រទ្រូងអីទេ?

ហៀង: អានិងដូចខ្ញុំបានជំរាបអញ្ចឹង វាខ្សោយដែរខ្ញុំ ជំងឺខ្ញុំវាខ្សោយដែរណា៎ សំរានក៏សំរានមិនលក់ដែរ ហើយខ្ញុំផ្លាសសាយញឹកណាស់ គិតពេក

សុជាតិ: ពូខឹងខ្លាំងរឺតិចពេលដែលពូនឹកឃើញអញ្ចឹង?

ហៀង: ខឹង

សុជាតិ: ខឹងខ្លាំងរឺតិច?

ហៀង: ខ្លាំង ប្អូនឯងក៏ដឹងដែរ ហើយមិនទាន់យកឪពុកម្តាយទៅសម្លាប់ក៏មិនដឹងដែរ ទាល់តែអ្នកដឹងបានថា

សុជាតិ: ពូចេះតែមានអារម្មណ៍ថាអ្នកដទៃទៀតយល់អត់ច្បាស់ពីហេតុការណ៍ដែលកើតឡើងចំពោះពូណា ពូយល់អញ្ចឹងទេ? ហេតុការណ៍ដែលកើតឡើងពីសម័យប៉ុលពតអញ្ចឹងណា ពូចេះតែយល់ថាអ្នកដទៃយល់មិនច្បាស់ពីអារម្មណ៍របស់ពូទេ?

ហៀងៈ គេដោយគេ គេមិនដែលវេទនាគេមិនដែលនឹកនារឿងអញ្ចឹងទេ យើងមិនសូវនិយាយគេមិនសូវដឹងដែរនិង

សុជាតិៈ ពូអត់ដែលប្រាប់គេទេហេះ?

ហៀងៈ អត់ទៃ អ្នកខ្លះគេដឹងពីអារម្មណ៍របស់យើងដែរ ជួនកាលមិត្តភក្ត្ររបស់យើង គេយល់ពីអារម្មណ៍របស់យើងដែលគេប្រាប់យើង គេដឹងថាយើងមានអារម្មណ៍អញ្ចឹង ទៅ

សុជាតិៈ អញ្ចឹងគេដឹងដែរ?

ហៀងៈ គេដឹង ថាអារម្មណ៍របស់យើងយ៉ាងម៉ិចៗ គេដឹងដែរ

សុជាតិៈ ពូមានដែលពិបាកមានការបំពេញមុខងារប្រចាំថ្ងៃរបស់ពូទេរាល់ថ្ងៃនិង?

ហៀងៈ ខ្ញុំរកស៊ីអញ្ចឹង ជួនកាលភ្លេចមុខភ្លេចក្រោយដែរ គិតណា៎ ជួនកាលពិបាកអញ្ចឹងទៅ

សុជាតិៈ ពិបាកខ្លាំងទេពូ

ហៀងៈ គិតថាវាពិបាក ការរស់នៅគ្រួសារវាពិបាកមួយចប់ ភ្លេចនោះភ្លេចដែរតើ ជួនអីបើគិតមែនទែន ជួនកាលថ្ងៃក្រោយអត់ស្គាល់ប្អូនក៏មានដែរ ភ្លេច

សុជាតិៈ ពូភ្លេចខ្លាំងទេ?

ហៀងៈ ខ្លាំងតែម្តង

សុជាតិៈ ពេលគេប្រាប់ពូថាពូបានធ្វើអ៊ីមួយអីមួយភ្លេចតែម្តង?

ហៀងៈ ភ្លេចតែម្តង អត់មានចាំទេ ជួនកាលភ្លេចយូរ ទាល់តែយកដៃសង្កត់អញ្ចឹងទៅទើបនឹកឃើញ ថាអារម្មណ៍មិនមូលណា អារម្មណ៍មិនមូល ថាអារម្មណ៍ម្នាក់ៗ មិនបានជួបជុំ គិតឃើញថាការរស់នៅជីវភាពគ្រួសារមិនគ្រប់គ្រាន់ នឹកឃើញមែនតើ ហើយដល់រាំងអញ្ចឹងទៀតវាវេទនាអញ្ចឹងតែម្តង មិនដឹងជាទៅឯណា

សុជាតិៈ អញ្ចឹងពូចេះតែស្តីបន្ទោសខ្លួនឯងទេការដែលនឹកឃើញដល់ការឈឺចាប់កាលពីជំនាន់ខ្មែរក្រហមអញ្ចឹង?

ហៀងៈ អត់ទេ ខ្ញុំថាចិត្តខ្ញុំចង់ធ្វើការពលកម្មអស់ពីចិត្តកាយហើយណា៎ តែគេមិនពេញចិត្តថាយើងធ្វើការមិនឲ្យអស់ពីសមត្ថភាព តែយើងធ្វើអស់ហើយ សុខចិត្តអត់បាយបបរក៏យើងមិនធុញទ្រាន់តែគេនៅតែថាយើង

សុជាតិៈ អូ! ធ្វើការច្រើនតែគេថាមិនគ្រប់ទៀត?

ហៀងៈ បាទ អ្នកថាខ្ញុំនិងដូចខ្ញុំបានជំរាបអញ្ចឹងគឺតាមើកនិង កូនខ្ញុំនៅទីង ដល់ពេលវាពេញវ័យទៅវាដឹង វានិងអាមើកនិងធ្វើបាបឪខ្ញុំ តែខ្ញុំថាអប់រំកូន កាលពីមុនឆ្នាំ៨០ជាងវាជិះកង់មក វាទីងណាស់ ធ្វើបាបឪពេកណា៎ ដល់ហើយខ្ញុំថាកូនឯងកុំធ្វើបាប

លែងមានកំហឹងឈឺចាប់អី អញ្ចឹងបានវាចោលទៅ និងលែងខឹងទៅឪពុកម្ដាយអប់រំលែងមានកំហឹងទៅ ធ្វើម៉ិចសគ្គមវាទៅអញ្ចឹងទៅហើយ ខ្ញុំអប់រំកូនរហូត កូនខ្ញុំខឹង តើហើយបើមីមួយនេះនៅប៉ុលពតលង់ទឹកដែរ លង់ទឹកវាលស្រែឆិចៗនិង លង់ទឹកម៉ោង១០យប់ណាំទើបរកបាយណាំ គេមិនឲ្យបាតផង លង់ទឹកលង់អីនិងវេទនា ណាស់ហើយខ្ញុំនៅតាមកងក៏គេមិនហ៊ានឲ្យមក អញ្ចឹងថាវេទនាណាស់ បើនិយាយពីរឿងប្រវត្តិនិងវេទនាមែនទែន ខ្ញុំមិនចង់នឹកនាដល់ជំនាន់និងដែរតែប្អូនបានមកសម្ភាសន៍ខ្ញុំហើយខ្ញុំជួយប្រាប់ទៅណាំ

សុជាតិៈ បាទ បាទ

ហៀងៈ រាល់ថ្ងៃខ្ញុំមិនចង់លឺទេ មិនចង់ឲ្យឃើញទៀត ធ្វើបុណ្យហើយដុតមិនចង់ ឲ្យជួបទៀត

សុជាតិៈ ពូរាល់ថ្ងៃពូចេះតែស្ដីបន្ទោសខ្លួនឯងដែលបានរស់មកដល់ឥឡូវទេ អ្នកខ្លះគេថា បើស្លាប់ពីជំនាន់ប៉ុលពតមកប្រហែលជាគ្រាន់បើជាងឥឡូវ ពូមានដែលមានអារម្មណ៍អញ្ចឹងទេ?

ហៀងៈ អត់ទេ បន់ឲ្យតែរស់ទេ បើរបបប៉ុលពតនិងនៅយូរទៀត អ្នកពេញសិទ្ធិនិងក៏មិនរស់ដែរ មិនរស់ដូចតែគ្នា គេស្រាវជ្រាវទៅថាវានៅពាក់វាក់វិនជាមួយគ្នានិងគ្មាននរណាបាននៅរស់ទេ

សុជាតិៈ សព្វថ្ងៃពូចេះតែមានអារម្មណ៍អស់សង្ឃឹមដែរទេពូ?

ហៀងៈ យី បើរាំងអស់សង្ឃឹម មិនដឹងជាទៅនៅឯណាទេខ្ញុំ បើសិនជារាំងវិញ

សុជាតិៈ អស់សង្ឃឹម អស់តិចតួច ខ្លាំង រឺល្មមទេ?

ហៀងៈ ទេ អត់មានសង្ឃឹមតែម្ដង

សុជាតិៈ អញ្ចឹងបានន័យថាអស់សង្ឃឹមខ្លាំងហេះ?

ហៀងៈ បាទ អានិងបើសិនជាមានភ្ញៀងអីទៅក្រែងលោរស់នៅបានខ្លះ ជួបផ្គត់ផ្គង់គ្រួសារបានខ្លះ បើសិនជារាំងវិញអត់តែម្ដង ហើយកូនដឹងស្រាប់ហើយ កូនទៅតូចៗដឹងតែហូប ដឹងតែស្លៀកពាក់ហើយយើងមិនដឹងជាទៅរកអី

សុជាតិៈ ពូចេះតែខ្មាស់អៀនខ្លួនឯងទេ ចំពោះហេតុការណ៍ដែលឈឺចាប់ដែលកើតមានចំពោះពូ?

ហៀងៈ ខ្មាស់អៀនយ៉ាងម៉ិច

សុជាតិៈ ខ្មាស់អៀនអ្នកដទៃដែរទេពូ?

ហៀង: បាទ ខ្មាស់ យើងខំធ្វើល្អតែដល់ពេលកេចោទយើងមិនដឹងជាធ្វើយ៉ាងម៉ិចទេ ធ្វើការអត់មានពេលអង្គុយជក់ថ្នាំ ដល់ម៉ោងគេឲ្យសំរាកបន្តិចបន្តួចទៅទៀតហើយ វាទូទៅតែខ្មាស់ដែរដូចថា អ្នកគ្រប់គ្រងយើងពីមុនដូចថាគេយកតាមវណ្ណៈណា អ្នកនិងធ្លាប់វេទនា ធ្លាប់ពឹងយើង ធ្លាប់រកយើង ហើយមកត្រួតយើងស្តីយើងខ្មាស់ដែរ គេមកថាយើង ចង់មកស្តីយើងថ្មើម៉ានបានថ្មើនិង ខ្មាស់ដែរនិងតែមិនដឹងធ្វើយ៉ាងម៉ិច

សុជាតិ: ពូចេះតែចំណាយពេលគិតឆ្ងល់ថាហេតុអីបានជារឿងទាំងអស់និងកើតឡើងចំពោះពូ ពូមានដែលឆ្ងល់អញ្ចឹងទេថ្មីៗនិង?

ហៀង: កាលពីជំនាន់ប៉ុលពតនិងអញ្ចឹងបានជាខ្ញុំចំណាយពេលជាមួយគ្រួសារអីថា បើប៉ុលពតទាំងអស់គ្នាកូនទាំងអស់និងក៏មិនបានទៅ ហើយឪទាំងអស់និងក៏មិនបានទៅដែរ ស្លាប់ទាំងអស់ បងប្អូនទាំងអស់ក៏មិនបានរស់នៅដែរ

សុជាតិ: ពូចេះតែឆ្ងល់ដែរហេះ?

ហៀង: យើងមិនឆ្ងល់ទេ តែបើក្មេងៗឆ្ងល់

សុជាតិ: ពូមានអារម្មណ៍ថាមានតែពូម្នាក់ទេដែលទទួលរងការឈឺចាប់បែបនិងរឺមានអ្នកដទៃដែរ?

ហៀង: ដូចយាយនេះអីប្តីគេយកទៅសម្លាប់ហេះ

សុជាតិ: អញ្ចឹងពូគិតថាមិនមែនមានតែឯងទេ?

ហៀង: មិនមែនមានតែឯងទេ ដូចផ្ទះនេះអីគាណាំកុងណាំអីមួយអញ្ចឹងទៅ ហើយប្តីគាត់ធ្វើគ្រូបង្រៀន

សុជាតិ: ពូរាល់ថ្ងៃមានដែលមានអារម្មណ៍ថា អ្នកដទៃសុទ្ធតែជាសត្រូវរបស់ពូទេ?

ហៀង: អត់ទេ បើបានគ្នាមកនិយាយគ្នាលែងអញ្ចឹងទៅ គ្រាន់បានធូរចិត្តខ្លះ អត់មាននិយាយរឿងនយោបាយអីទេ និយាយលែងហូបចុកអីធម្មតា សប្បាយអីអញ្ចឹងទៅ អត់មាននិយាយពីរឿងអីទេ

សុជាតិ: ពូមានអារម្មណ៍ថាដូចជាគ្មាននរណាម្នាក់គួរឲ្យទុកចិត្តបាន ពឹងពាក់បានទេពូ?

ហៀង: ហ៊ឺ មានតែបងប្អូនមានអីនិង រឿងការពឹងពាក់ ទៅពឹងពាក់គេក៏ពិបាកដែរ ដូចថាមិនមែនបងប្អូនយើងបង្កើតណា៎

សុជាតិ: អញ្ចឹងពូចេះតែមានអារម្មណ៍ថា ខ្លួនពូបែកចេញជាពីរ ម្នាក់ជាអ្នកធ្វើ ហើយម្នាក់ទៀតជាអ្នកចាំតែបញ្ជាណា ពូមានដែលមានអារម្មណ៍អញ្ចឹងទេ? ដូចថាធ្វើអីមួយចេះតែស្ទាក់ស្ទើរៗណា៎? ថ្មីៗនិង?

ហៀង៖ ខ្ញុំបានជំរាបប្អូនថា របបយើងរហូតមកដល់បច្ចុប្បន្ននេះណា៎ វាពិបាកនិយាយដែរ ដូចថាយើងនិយាយទៅខុសចាប់ចំណុចដែរ ខ្លះឥឡូវប្ដីង អញ្ចឹងឥឡូវសូម្បីតែឪពុកឯងបង្កើតក៏ប្ដឹងដែរ ឪប្ដឹង កូនប្ដឹង ចាប់ចំណុច ប្ដឹងយកទ្រព្យសម្បត្តិអញ្ចឹងទៅរឺថាឪធ្វើទារុណកម្មរាដេកពេទ្យអញ្ចឹងទៅមាន អាកូនប្ដឹងឪមានច្រើនណាស់

សុជាតិ៖ អញ្ចឹងសព្វថ្ងៃនិងពូចេះតែមានអារម្មណ៍ថា អ្នកដែលពូទុកចិត្តហើយបែកជាក្បត់ចិត្តពូវិញ មានអារម្មណ៍អញ្ចឹងទេ?

ហៀង៖ អត់មានទេ យើងមើលចិត្តគេក៏មិនដឹងដែរ យើងមិនដឹងពីចិត្តរបស់គេយ៉ាងម៉ិច យើងមិនដឹងពីចិត្តរបស់គេដែរ មិនទុកចិត្តមួយរយភាគរយដែរ

សុជាតិ៖ អញ្ចឹងកាលពីសម័យខ្មែរក្រហមពូដែលឃើញឈ្លបខ្មែរក្រហមអីចាប់រំលោភនារីភេទដែរទេពូ?

ហៀង៖ មានឃើញ ឃើញដើរបណ្ដើរហើយគេចាប់ ហៅយកទៅអញ្ចឹងទៅមានឃើញតើតែមិនដឹងជាគេយកទៅឯណា................

សុជាតិ៖ ពូឃើញតែម្ដងរឺយ៉ាងម៉ិច?

ហៀង៖ មិនមែនឃើញផ្ទាល់ទេ តែគ្រាន់តែដឹង យើងនៅកងយើងដឹង

សុជាតិ៖ កាលនិងយ៉ាងម៉ិច គាត់ដឹកអង្ករទ្រីន?

ហៀង៖ បាទដឹកអង្ករទ្រីននៅបន្ទន់ ឈ្មោះតាងែតនិង គាត់ដឹងកំហុស គាត់ប្រធានកង ហើយដល់ពេលអញ្ចឹងទៅវាបែកការអញ្ចឹងទៅ ដល់នឹកឃើញថាមិនឲ្យយកទៅសម្លាប់ចុះប្រធានកងគេវាពេញសិទ្ធច្បាស់ណា ឡើងទៅដឹកអង្ករទ្រីននៅបន្ទន់ស្លាប់ទៅ

សុជាតិ៖ ហើយចុះស្រីគេធ្វើអីដែរ?

ហៀង៖ ស្រីគេមានប្ដីទៅ ប្ដីគេនៅតើ

សុជាតិ៖ ឥឡូវស្រីនិងគាត់នៅតើអី?

ហៀង៖ បាទ គាត់នៅតើ

សុជាតិ៖ ឈ្មោះអីដែរ?

ហៀង៖ ឈ្មោះ ណាត

សុជាតិ៖ នៅភូមិណាដែរ?

ហៀង៖ ................

សុជាតិ៖ កន្លែងខ្ញុំនិងគេបានជួបសម្ភាសន៍ជាមួយមីងម្នាក់នៅខេត្តកំពង់ឆ្នាំងណា៎ ឥឡូវគេផលិតជាខ្សែភាពយន្តទៀត គេសម្ភាសគាត់អញ្ចឹងទៅ ហើយថតរូបគាត់ គាត់សុខចិត្តនិ

យាយព្រោះគាត់យល់ថា អានិងជាប្រវត្តិសាស្ត្រដើម្បីឲ្យក្មេងជំនាន់ក្រោយដឹងថា ទព្វខ្មែរក្រហមនិងបានបំពារបំពានរាងកាយគាត់ៗ តែការរំលោភនោះមិនមែនជាការរំលោភធម្មតាទេ ខ្លាំងជាងនិងទៀត ទព្វខ្មែរក្រហមប៉ុន្មាននាក់និង គេរៀបយកគាត់ទៅសម្លាប់ហើយ តែមុននិងសម្លាប់គេរំលោភគាត់សិនកាលនោះ តែកាលនោះគាត់រួចមកវិញដោយសារមានទាហានខ្មែរក្រហមម្នាក់ចិត្តធម៌ដែរពូ ទាហានឲ្យនិងឲ្យគាត់រត់ចេញពីកន្លែងនិងហើយរួចខ្លួនរហូតដល់សព្វថ្ងៃនិង ហើយគាត់បានមកនិយាយប្រាប់ពួកខ្ញុំហើយបានបង្កើតជាខ្សែភាពយន្តមួយ អញ្ចឹងកាលពីជំនាន់ប៉ុលពតនិងពូបានជួបប៉ុន្មានករណីដែរ?

ហៀង៖ ខ្ញុំបានជួបតែមួយនិងទេ

សុជាតិ៖ ហើយចុះមួយទៀតនោះ?

ហៀង៖ មួយទៀតមានការសង្ស័យគេយកទៅដកចេញពីប្រធានកងទៅ

សុជាតិ៖ អូ! គ្រាន់តែសង្ស័យទេហេះ?

ហៀង៖ សង្ស័យវាជាក់ស្តែង តែគេលាក់លៀមខ្លះទៅ ដកសិទ្ធយើងជាប្រធានកងចេញ ហើយមួយទៀតដឹងតែស្លាប់តែម្តង សម្លាប់ខ្លួនឯងនៅភូមិប៉ែនមាសឈ្មោះណាតនិងប្រពន្ធគេ ប្តីគេនៅសព្វថ្ងៃនិងរាល់ថ្ងៃយកគ្នាវិញទៅ

សុជាតិ៖ ប្តីគាត់និងគាត់ធ្វើដែរ កាលពីជំនានប៉ុលពតនិង? គាត់ជាកម្មាភិបាលនិងដែររឺក៏ប្រជាជន?

ហៀង៖ បានបែបកម្មាភិបាលនិងដែរហើយពីព្រោះប្រពន្ធវាប្រធានកង តែប្រពន្ធប្រធានកងប្តីក៏ប្រធានកងដែរ

សុជាតិ៖ អញ្ចឹងពូខ្ញុំចង់សួរសំនួរពូខ្លះទៀតទាក់ទងនិងការយល់ឃើញរបស់ពូណា ពូយល់ឃើញយ៉ាងម៉ិចក៏បានដែរ ពូមានដែលលឺដំណឹងពីការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរទេសព្វថ្ងៃនិង?

ហៀង៖ អត់

សុជាតិ៖ អត់ដែលលឺទេ?

ហៀង៖ ដែលតែស្តាប់តាមវិទ្យុកាត់ទោស

សុជាតិ៖ ពូលឺតាំងពីអន្កាលមក?

ហៀង៖ ចេះតែលឺគេផ្សាយតាវិទ្យុនិង

សុជាតិ៖ លឺយូរហើយរឺទើបតែលឺទេ?

ហៀង៖ លីយូរដែរហើយ

សុជាតិ៖ អញ្ចឹងពូលីយូរហើយ តែដល់មកឥឡូវមិនទាន់កាត់ទោសកាត់អីអញ្ចឹង......?

ហៀង៖ បាទ លឺសូរតែកាត់ទោសតែនៅដដែល

សុជាតិ៖ អញ្ចឹងពូមានអារម្មណ៍យ៉ាងម៉េចដែរពេលដែលលីយូរហើយបែជាមិនទាន់កាត់ទោសអញ្ចឹង?

ហៀង៖ អានេះយើងជាប្រជាជនវាពិបាកណាស់ នៅលើថ្នាក់ដឹកនាំទៅរាជរដ្ឋាភិបាល យើងជាប្រជាជនមិនដឹងទេ អានិងជារឿងរាជរដ្ឋាភិបាល

សុជាតិ៖ ពូមានដែលធ្លាប់លឺឈ្មោះមេដឹកធំៗខ្មែរក្រហមណាខ្លះដែរ?

ហៀង៖ ខ្ញុំលឺសូរតែតាម៉ុក

សុជាតិ៖ ហើយនរណាទៀត?

ហៀង៖ អៀង សារីអីនិង ហើយប៉ុន្មាននាក់ទៀតខ្ញុំអត់ដឹងទេ

សុជាតិ៖ ចុះប៉ុលពតមានដែលលឺឈ្មោះគាត់ទេ?

ហៀង៖ បាទ លឺ ប៉ុលពតលឺសូរតែតាម៉ុកៗនិង ធ្លាប់យកដើរត្រួតត្រាមើលផ្ទះ បើក្រៅពីនិងខ្ញុំអត់ដែលស្គាលទេ

សុជាតិ៖ ចុះខៀវសំផន

ហៀង៖ បាទ គ្រាន់លឺតែឈ្មោះតែខ្ញុំអត់ដែលស្គាល់ទេ

សុជាតិ៖ ពូលឺនរណាខ្លះអញ្ចឹង?

ហៀង៖ ខ្ញុំលឺតែតាម៉ុក

សុជាតិ៖ តាម៉ុកនិងលឺជាងគេ?

ហៀង៖ តាម៉ុកលឺហើយដែលឃើញទៀតនៅតាមកងវែកប្រឡាយ កាន់ទំពក់មួយដើរបញ្ជារ

សុជាតិ៖ អូ! កាន់ទំពក់

ហៀង៖ បាទ កាន់ទំពក់មួយដើរបញ្ជាតែម្តង

សុជាតិ៖ គាត់ដើរបញ្ជានិងកាចដែរទេ រឺមួយក្នុងលក្ខណៈស្លូតបូតទេ?

ហៀង៖ កាច តាម៉ុកកាច បាទ តាម៉ុកនិងអត់បានទេ កាច បើក្រៅពីនិងលឺសូរតែមានតែឈ្មោះទេ ខ្ញុំអត់ដែលឃើញទេ អៀងសារីនិងអត់ដែលឃើញទេ លឺសូរតែឈ្មោះទេ

សុជាតិ៖ ចុះឥឡូវពូមានដឹងទេ តាម៉ុកនិងនៅឯណាឥឡូវ?

ហៀង៖ អត់ដឹងទេ ដឹងតែកាត់ទោសតាម៉ុកៗ

សុជាតិ៖ តាម៉ុកគាត់មិនទានកាត់ទោសទេ គាត់គ្រាន់តែជាប់ឃុំឃាំង

ហៀង៖ ចុះពេលសួរគេខ្លះគេថា តាម៉ុកនៅផ្ទះនៅអីណា?

សុជាតិ៖ អត់ទេ តាម៉ុកឥឡូវកំពុងជាប់ឃុំរង់ចាំការកាត់ទោស ជាប់ឃុំ២នាក់រាល់ថ្ងៃនិង តាម៉ុកហើយនិងឌុច

ហៀង៖ រាល់ថ្ងៃប្រជាជនគេចាំមើលថា កាត់ទោសតាម៉ុកកើតអត់

សុជាតិ៖ តាមខ្ញុំគេអាចនិងកាត់បានហើយព្រោះឥឡូវរដ្ឋាភិបាលគាត់ត្រូវគ្នាហើយ

ហៀង៖ បាទ អញ្ចឹងបានម្នាក់ៗចាំតែមើលថា តើគេកាត់ទោសខ្មែរក្រហម តាម៉ុកបានរឺអត់

សុជាតិ៖ អញ្ចឹងពូមានដឹងខ្មែរក្រហមធំៗណាខ្លះដែលស្លាប់ មេដឹកនាំណាខ្លះដែលនៅរស់ពូ?

ហៀង៖ មេដឹកនាំ.....ខ្ញុំមិនដឹងទេ..

សុជាតិ៖ បាទ ប៉ុលពតស្លាប់ហើយ

ហៀង៖ អៀង សារីនៅទេ

សុជាតិ៖ បាទ ខៀវ សំផននៅ

ហៀង៖ បាទ ខៀវ សំផននៅទេ

សុជាតិ៖ តាម៉ុកនៅដែរ តែជាប់ឃុំ

ហៀង៖ តែអៀងសារីអត់ជាប់ឃុំទេហេះ?

សុជាតិ៖ បាទ គាត់អត់ទេ

ហៀង៖ គាត់ធ្វើការ?

សុជាតិ៖ អត់ទេ គាត់នៅប្រជាជនធម្មតា

ហៀង៖ ថ្ងៃមុនអៀងសារីមកកន្លែងនេះកាលពីលើកមុន

សុជាតិ៖ អូ! គាត់មកធ្វើអី? គាត់អត់មានដំណែងអីក្នុងរាជរដ្ឋាភិបាលអីទេ?

ហៀង៖ គាត់មកមានអង្គរក្សច្រើនណាស់

សុជាតិ៖ បាទ អានិងគាត់មកធម្មតា គាត់មានលុយ

ហៀង៖ បាទ អានិងអៀងសារីខ្ញុំឃើញ ខ្ញុំអត់ស្គាល់អៀងសារីផងនិង

សុជាតិ៖ មកវត្តនេះពូហេះ?

ហៀង៖ បាទ មកវត្តនិងលឺថាលោកមួយអង្គត្រូវជាបងប្អូនកូនប្រសារគាត់និងសុគត ដល់ ហើយ មកតែមួយភ្លែតនិង

សុជាតិ៖ មកយូរហើយពូហេះ?

ហៀង៖ ប្រហែលជា២ឆ្នាំហើយ?

សុជាតិ៖ គាត់មកធ្វើអីដែរ?

ហៀង៖ មកចូលបុណ្យ កូនប្រុសរបស់អៀងសារីត្រូវជាចៅតានិង អញ្ចឹងដល់ពេលតានិងសុគត់ គាត់មកធ្វើបុណ្យនៅថ្ងៃស្លាប់និងតែម្តង

សុជាតិ៖ អញ្ចឹងអៀងសារីខៀវសំផននៅ?

ហៀង៖ បាទ

សុជាតិ៖ ហើយអៀងសារី ខៀវសំផននៅ ហើយសុនសេនកាលពីមុនជារដ្ឋមន្ត្រីការពារជាតិ ឥឡូវគាត់ស្លាប់ហើយ

ហៀង៖ បាទ

សុជាតិ៖ ពូមានដែលលឺឈ្មោះសុនសេនទេ?

ហៀង៖ បាទ ធ្លាប់តែលឺនិង តែមិនដែលឃើញផងខ្ញុំ ខ្ញុំមិនសូវចាប់អារម្មណ៍ដែរថ្នាក់ដឹកនាំ ខ្ញុំដឹងតែថ្នាក់កង ដល់ថ្នាក់លើគេមិនដែលមកធ្វើបាបយើងដែរ មានតែកងនិងធ្វើ បាបយើង ហើយកំហឹងខ្ញុំអត់មានទឹងមេដឹកនាំថ្នាក់ណាទេ កំហឹងបំផុតគឺមេដឹកនាំថ្នាក់ ក្រោមនិងតែម្តង អ្នកធ្វើបាប អ្នកយកវ៉ៃគឺកងនិងតែម្តង

សុជាតិ៖ អញ្ចឹងពូការកាត់ទោសខ្មែរក្រហមនិង គេប្រុងនិងកាត់ទោសតែអ្នកធំៗទេ អត់កាត់ អ្នកតូចៗនៅតាមកងអីទេ អញ្ចឹងពូចង់ឲ្យគេកាត់ទោសអ្នកធំៗនៅខាងលើរឺក៏កាត់ ទោសអ្នកក្រោមៗដែរ?

ហៀង៖ ហ៊ឺ ខ្ញុំបានជំរាបហើយថា រឿងកាត់មិនកាត់អានិងស្រេចលើរាជរដ្ឋាភិបាលទៅ ដូច ខ្ញុំជំរាបថាខ្ញុំអត់មានកំហឹង ខ្ញុំឈប់ អាស្រ័យលើគេចុះ

សុជាតិ៖ ច្បាប់គេចែងថាមិនកាត់អ្នកតូចៗទេ ដោយខ្លាចពាក់ព័ន្ធច្រើនពេក

ហៀង៖ យើងខ្ញុំនៅបានតែប៉ុណ្ណឹងសុខហើយ

សុជាតិ៖ បាទ អញ្ចឹងពូយល់ថាការកាត់ទោសខ្មែរក្រហមជាការសងសឹកដែរទេពូ?

ហៀង៖ អានេះការកាត់ទោស រឿងសងសឹកមិនដឹងជាយ៉ាងម៉ិចហក បើថ្នាក់ដឹកនាំដឹងពីកំ ហឹងប្រជាជនខ្លាំងឯងណេះទៅ........ដោយសារវេទនាខ្លាំង

សុជាតិ៖ អញ្ចឹងការកាត់ទោសនិងជាការសងសឹកដែរពូហេះ?

ហៀង៖ ខ្ញុំថាកាត់ទោសគ្មានការសងសឹកទេ ខ្ញុំថាបើកាត់ទោសមិនសម្លាប់ទេ

សុជាតិ៖ បាទ មិនសម្លាប់ទេ ច្បាប់យើងអត់មានកាត់ទោសប្រហារជីវិតទេ គ្រាន់តែដាក់ ទោសមួយជីវិត

ហៀង៖ អានិងផ្នែកនយោបាយ ការគ្រប់គ្រងបំផ្លាញ សម្លាប់ប្រជាជន អានឹងកាត់ទោស របៀបម៉ិចខ្ញុំអត់ដឹងទេ

សុជាតិៈ អញ្ចឹងបើសិនជាការទោសមេដឹកនាំខ្មែរក្រហមអញ្ចឹង អាចមានប៉ះពាល់ដល់ស្ថេរភាពស្រុកយើងដែរទេពូ ពូយល់ឃើញថាអាចមានទេ?

ហៀងៈ ដូចជាគ្មានទេ ប្រជាជនម្នាក់ៗដូចជាមិនសូវនឹកនាចាប់អារម្មណ៍ទេ

សុជាតិៈ អូ!

ហៀងៈ ដូចខ្ញុំក៏ដោយបងប្អូនខ្ញុំតាមមូលដ្ឋានអីក៏គ្មានការចាប់អារម្មណ៍ដែរ គ្មានការភ្ញាក់ផ្អើលអីទេ ខ្ញុំចង់កាត់ទៅតែដល់គេអ្នកផ្សេងទៅធ្លាប់សប្បាយ កូនចៅផ្ទាល់គេធ្លាប់ សប្បាយធ្លាប់មានបុណ្យស័ក្កទៅក្រែងលោវាយ៉ាងម៉ិចខ្ញុំអត់ដឹងទេ អានិងវាគាម និងដែរ

សុជាតិៈ បាទ ពូយល់ថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រមនិងអាចមានទេពូ អាចកើតមានទេ?

ហៀងៈ លឺសូរតែកាត់ទោសតែមិនដឹងយ៉ាងម៉ិចឥ

សុជាតិៈ អាចនិងកើតមានទេពូ?

ហៀងៈ អាចកើតមានទៅតែមិនដឹង.......

សុជាតិៈ អញ្ចឹងអានិងកើតមានដែលហេះតាមពូណា?

ហៀងៈ មាន តែដឹងគេកាត់អន្តាល មិនហ៊ានថា លឺសូរតែកាត់ទោសៗតែមិនដឹងអន្តាល់

សុជាតិៈ បាទ ប្រហែលជានិងអាចឆាប់ៗនិងដែរហើយ

ហៀងៈ បាទ និងអាលកាត់ទោស..........

សុជាតិៈ អញ្ចឹងពូយល់ថាការកាត់ទោសខ្មែរក្រហមនិងជាការចាំបាច់រឺអត់ណា?

ហៀងៈ អនិងខ្ញុំមិនហ៊ានថាដែល តែខ្ញុំថាចាំបាច់

សុជាតិៈ បាទ ព្រោះអីគាត់សម្លាប់មនុស្សច្រើនដែរ

ហៀងៈ បាទ កាត់ទោសនិងដាក់ក្នុងសមាសភាពណាមួយរឺកំណត់ឆ្នាំយ៉ាងណាខ្ញុំមិនហ៊ានថាទេ តែអាចត្រូវកាត់ឲ្យប្រជាជនអស់ចិត្តណា មេដឹកនាំយើងការគ្រប់គ្រងប្រទេសនិងយើងសម្លាប់យ៉ាងម៉ិច ធ្វើធ្វើឲ្យប្រទេសនិងហិនហោចយ៉ាងម៉ិច

សុជាតិៈ អញ្ចឹងពូ គេកាត់ទោសមេដឹកនាំខ្មែរក្រហមអញ្ចឹង អាចធ្វើឲ្យប្រជាជនយើងស្ងប់អារម្មណ៍ដែរទេ?

ហៀងៈ ប្រជាជនខ្លះ.........

សុជាតិៈ ដូចថាអ្នកខ្លះមានឪពុកម្តាយគេយកទៅសម្លាប់អញ្ចឹងហើយពេលដែលកាត់ទោសមេដឹកនាំខ្មែរក្រហមអញ្ចឹងធ្វើឲ្យគាត់និងរសាយ បំបាត់ការគិតច្រើនអីដែរទេពូ ពូយល់ថាអញ្ចឹងទេ?

ហៀង៖ ខ្ញុំថាបើគាត់ទោសអ្នករងគ្រោះអ្នកវេទនាអញ្ចឹងទៅណា ហើយអ្នករងគ្រោះគាត់ទោសនិងអរអញ្ចឹងទៅ ដូចថាអ្នកមានបណ្តាស័កធំៗ ដូចជាប្រធានកងធំៗធ្វើបាបគ្រួសារគេ ក៏គេអត់សប្បាយចិត្តដែរដែរ

សុជាតិ៖ អញ្ចឹងពូពាក្យថាយុត្តិធម៌មានន័យថាម៉ិចដែរពូ?

ហៀង៖ យុត្តិធម៌មិនលំអៀង ត្រឹមត្រូវការពិត

សុជាតិ៖ ពូចង់ឲ្យមានយុត្តិធម៌នៅក្នុងសង្គមដែរពូ?

ហៀង៖ បាទ ខ្ញុំចង់ដែរនូវការពិត

សុជាតិ៖ ចុះបើសិនជាតុលាការនិងកើតមាន ពូសង្ឃឹមថាមានយុត្តិធម៌ដែរទេ? ពូគិតថាអាចរកយុត្តិធម៌ឲ្យប្រជាជនខ្មែរយើងបានទេ?

ហៀង៖ បើគាត់ទោសខ្ញុំថាអាចរកយុត្តិធម៌ដែរ គាត់និង រកការពិតណា៎

សុជាតិ៖ ចុះការបង្រួបបង្រួមមានន័យថាម៉ិចដែរ?

ហៀង៖ អានេះការបង្រួបបង្រួមអស់ការទាស់ទែងគ្នា សាមគ្គីគ្នាហើយអានិង

សុជាតិ៖ អញ្ចឹងពូធ្វើម៉ិចដើម្បីឲ្យប្រជាជនបង្រួមបង្រួមគ្នា កុំឲ្យទាស់ទែងគ្នា តើត្រូវធ្វើម៉ិចទៅ?

ហៀង៖ ការបង្រួបបង្រួម ការសាមគ្គីគ្នានិងជាសៀងនូវការកុំក្រកាន់បក្សពួក អានិងការសាមគ្គីគ្នាធ្វើម៉ិចធ្វើម៉ិចឲ្យស្រលាញ់គ្នា អញ្ចឹងអត់មានទាស់ទែងគ្នាទេ

សុជាតិ៖ ពូរាល់ថ្ងៃឃើញនៅភូមិនិងមានការបង្រួបបង្រួមគ្នានៅ?

ហៀង៖ មានអត់ចេះទាស់ទែងគ្នាទេ នៅខាងៗនិងនៅលែងជាមួយគ្នានិង ដើរអត់ចេះទាស់ទេរឿងខ្ញុំមួយអត់ចេះទាស់ទេ បើក្រៅពីនិងក្រែងលោមាន តែខ្ញុំអត់មានទាស់ទេ

សុជាតិ៖ អូ! ក្រៅពីពូមានអ្នកប្រកាន់បក្សពួកដែរ?

ហៀង៖ មាន មានទាស់មានទែងមានឈ្លោះគ្នា ចំពោះខ្ញុំអត់ ផ្ទះមួយទៅផ្ទះមួយមាន បើចំពោះខ្ញុំអត់ទេ

សុជាតិ៖ អញ្ចឹងបើសិនជាអ្នកដែលសម្លាប់មនុស្សកាលពីជំនាន់ប៉ុលពតដូចជាប្រធានកងអីអញ្ចឹងណាតើពូចង់បង្រួបបង្រួមជាមួយពួកគេដែរទើបចង់ឲ្យគាត់រស់នៅដាច់តែឯង?

ហៀង៖ ខ្ញុំនិងហើយ គាត់នោះប្រធានកង ដល់ឃើញគេជិះកង់អីអញ្ចឹងទៅ ហៅគាត់ទៅ ខ្ញុំហៅបងគាត់ហៅបងដែរទៅ ខ្ញុំអត់មានការខឹងអីទេ ឥឡូវគេមកនិយាយជាមួយខ្ញុំធម្មតា ហៅប្អូនហៅអីទៅ កាលពីមុនមិនមែនហៅប្អូនអញ្ចឹងទេ ហ្អែងអីណោះ

ហើយឥឡូវហៅប្អូនលោកអីអញ្ចឹងទៅ ខ្ញុំហៅបងអញ្ចឹងទៅ ជាការធម្មតាធ្វើម៉េចឲ្យ មានការបង្រួបបង្រួមកុំឲ្យមានការទាស់ទែង អត់មានការខឹង មានការគុំគួនអីទេ

សុជាតិៈ អញ្ចឹងមេដឹកនាំខ្មែរក្រហមដែលនាំឲ្យមានការសម្លាប់មនុស្សច្រើនអញ្ចឹង យើងគួរតែ អត់ឪនឲ្យគាត់អត់ តាមគំនិតពូណា?

ហៀងៈ ខ្ញុំពិបាកថាណាស់ បើយើងថាអត់ឪនទៅក្រែងលោវា..........

សុជាតិៈ ចុះបើតាមគំនិតពូវិញ?

ហៀងៈ អានិងស្រេចតែលើរាជរដ្ឋាភិបាលទៅ

សុជាតិៈ បើសិនជាកាត់ទោសមេដឹកនាំខ្មែរក្រហមទៅតើអាចប៉ះពាល់ដល់ការបង្រួបបង្រួម ជាតិដូចថាអ្នកដែលធ្លាប់ជាកម្មាភិបាលចាស់ហើយដល់ឃើញគេកាត់មេអញ្ចឹងទៅ ចូលព្រៃម្តងទៀតទៅ តើអាចមានរឿងអញ្ចឹងទេ?

ហៀងៈ អានិងបើកាត់ទៅយើងកំណត់ទៅ យើងកំណត់ទៅតាមការអប់រំធ្វើម៉េចបើក្នុងសង្គម អប់រំទៅ លែងនៅ ពីមុនអញ្ចេះឥឡូវមកអប់រំបានប៉ុណ្ណេះល្អទៅ ខ្មែរដូចតែគ្នា អញ្ចឹងរឿងរដ្ឋាភិបាលខ្ញុំមិនហ៊ានជំរាប់ជូនទេ

សុជាតិៈ ពូសាសនាអាចធ្វើឲ្យប្រជាជនយើងបង្រួបបង្រួមគ្នាបានទេ?

ហៀងៈ អាច

សុជាតិៈ អាចយ៉ាងម៉េចទៅ?

ហៀងៈ ដូចថាសាសនាយើងវាបង្រួបបង្រួមនិយាយឲ្យប្រជាជន ចុះលោកទេសនាយើងមិន ដឹង សាមគ្គី កុំទាស់ទែង កុំលួច កុំប្លន់ ធ្វើម៉េចឲ្យសាមគ្គីគ្នា លោកទេសនា ការអប់ រំទៅផ្លូវធម៌ អត់មានឲ្យបញ្ហាប្រេះឆាគ្នា

សុជាតិៈ អញ្ចឹងបើពូដឹងថានរណាម្នាក់ដែលបានសម្លាប់ឪពុកម្តាយពូហើយ នៅរស់រហូតដល់ សព្វថ្ងៃ ពូអត់មានចង់សងសឹកគេវិញទេពូហេះ?

ហៀងៈ អត់ទេ

សុជាតិៈចុះកាលពីក្រោយឆ្នាំ៧៩មកពូមានចង់សងសឹកគាត់ទេ?

ហៀងៈ ហ៊ឺស ដូចខ្ញុំបានជំរាបអញ្ចឹង កូនខ្ញុំដឹងខឹង ធ្វើបាបឪ ស្លូវដែរនិងតែខ្ញុំអប់រំកូន

សុជាតិៈពូអត់មានគំនិតចង់សងសឹកអីទេហេះ?

ហៀងៈ អត់ទេ ខ្ញុំអត់ទេ ធ្វើការបើសង្គមអញ្ចឹង

សុជាតិៈចុះពេលទិវាចងកំហឹង២០ឧសភាអញ្ចឹង ពូមានដែលចូលរួមទេ?

ហៀងៈ បាទ ចូលរួម

សុជាតិៈកាលនិងពូនៅឯណា?

ហៀងៈ នៅអន្លុងគាសោម

សុជាតិៈពូចូលរួមនៅឯណា?

ហៀងៈ នៅសាលាដើមចំបក់...........

សុជាតិៈពូចង់មានមានពិធីនិងទៀតរឺចង់ឲ្យឈប់តែម្ដងពូ?

ហៀងៈ ខ្ញុំ រឿងការចងកំហឹងនិង កាលពីមុនចងកំហឹងរបបនិង របបប៉ុលពតនិង អញ្ចឹងខ្ញុំចងកំហឹងលែងឲ្យមានរបបនិង

សុជាតិៈ ការចងកំហឹងនិងជាការរំលឹកឲ្យមានការក្ដៅប្រហាយឡើងវិញរឺក៏យ៉ាងម៉ិចដែរ?

ហៀងៈ អានិងថាបើសិនជានឹកឃើញការឈឺចាប់កុំភ្លេចពីមុន

សុជាតិៈ ចុះបើយើងបង្រួបបង្រួមគ្នានិងហើយ តើត្រូវឲ្យមានទៀតរឺឈប់តែម្ដង?

ហៀងៈ ឲ្យឈប់តែ យើងធ្វើបុណ្យនិងថាកុំឲ្យភ្លេចពីមុន

សុជាតិៈ អូ! អញ្ចឹងត្រូវតែឲ្យមានរាល់ឆ្នាំអញ្ចឹងតែម្ដង

ហៀងៈ បាទ កុំភ្លេចធាតុដើម កុំភ្លេចការឈឺចាប់ តែអស់គុំគួនតែថាកុំឲ្យភ្លេចណា......អាចមានផលពីរ បើសិនជាធ្វើទៅក្រែងលោមានកំហឹង តែបើមិនធ្វើភ្លេច

សុជាតិៈ ចុះដែលសួរនាំពីប្រវត្តិឈឺចាប់កាលពីសម័យខ្មែរក្រហមអញ្ចឹងពូមានអារម្មណ៍យ៉ាងម៉ិចដែរ មានអារម្មណ៍យ៉ាងម៉ិច? ពូមានអារម្មណ៍យ៉ាងម៉ិចដែរពេលដែលខ្ញុំមករំលឹកអីអញ្ចឹង?

ហៀងៈ ខ្ញុំសប្បាយបានប្អូនមកសួរអញ្ចឹង ឲ្យមានការស្រាវជ្រាវអញ្ចឹងខ្ញុំមានការត្រេចកអរអញ្ចឹងណា

សុជាតិៈ ហើយសំដីរបស់ពូនិងខ្ញុំយកទៅចងក្រងដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង ព្រោះអីដល់ពេល១០០-២០០ឆ្នាំទៀតទៅ មានប្រយោជន៍ណាស់

ហៀងៈ ក្មេងក្រោយៗទៅវាអត់ដឹង ឲ្យចងក្រងឲ្យក្មេងដឹងថា កាលពីរដប្រហារ៧០រហូតដល់៧៩មកអាចនិងវេទនាប៉ុណ្ណា

សុជាតិៈ ពូមានដែលនិយាយរឿងនិងប្រាប់កូនចៅដែរទេ?

ហៀងៈ ខ្ញុំអប់រំដែរ លឺខ្ញុំថាទេ ថាខ្ញុំអប់រំកូនខ្ញុំ កូនសូម្បីតែអាចៅប៉ុណ្ណេះក៏ខស្សាហ៍ដាស់តឿនអប់រំ

សុជាតិៈ ហេតុអីពូ ដើម្បីអី?

ហៀងៈ	អប់រំវានៅការកំហឹង នៅការឈឺចាប់ របបនេះមានការឈឺចាប់ ពុក កូនឯងនៅប៉ុនេះ កូនឯងលង់ទឹកស្រែនេះ កូនឯងវេទនា អត់បាយម៉ោង១០អញ្ចឹងទៅ សុំបាយគេមិនបានឲ្យកូន

សុជាតិៈ	ពូដែលដែលក្មេងៗជិតខាងដែរហេះ?

ហៀងៈ	ក្មេងៗមកអញ្ចឹងជួនកាលប្រាប់ទៅ

សុជាតិៈ	ក្មេងៗជឿដែរពូហេះ?

ហៀងៈ	ជឿជួនកាលវាដឹង ឪពុកម្ដាយវាប្រាប់ តែខ្លះទៅដូចជាមាកូនធ្វើកងទព្វអញ្ចឹងណា អត់ដឹងថាឪពុកម្ដាយ ប្អូនរបស់យើងវេទនាម៉ិចអត់ដឹងទេ អ្នកនៅធ្វើទាហានណា អត់ដឹងទេ អត់ដឹងថាឪពុកវេទនាប៉ុន្មាន ស្ងួព្រលឹតស្ងួត្រកួនអីអត់ដឹងទេ ទាហាននិងដឹងតែពីឆ្អែតតែម្ដង អត់ដឹងទេ

សុជាតិៈ	ពូចង់ឲ្យក្មេងៗរៀនពីកម្មវិធីប្រវត្តិសាស្ត្រពីសម័យខ្មែរក្រហមនៅតាមសាលារៀនទេពូ?

ហៀងៈ	ខ្ញុំចង់ដែរ ចង់ឲ្យក្មេងរៀនដែរ សូម្បីតែសិស្សក៏ចង់ដឹងពីប្រវត្តិសាស្ត្រដែរ

សុជាតិៈ	បាទ មកដល់ឥឡូវនិងមិនទាន់មានកម្មវិធីសិក្សាពីរបបខ្មែរក្រហមឲ្យក្មេងរៀននៅឡើយទេ តែពូចង់ឲ្យក្មេងរៀន?

ហៀងៈ	បាទ ចង់ ចង់វាដឹង ហើយមិនចង់ឲ្យវាមានកំហឹងឈឺចាប់ចំពោះគុំគួនទេ ចង់ដឹងថារបបនេះវាធ្វើបាបអញ្ចេះ ចង់ឲ្យដឹងតែប្រវត្តិសស្ត្រ

សុជាតិៈ	ពូចង់ឲ្យក្មេងដឹងនិងដើម្បីអីដែរ?

ហៀងៈ	តែក្មេងនៅក្នុងមូលដ្ឋាននេះដឹង មិនមែនថាមិនដឹងទេ បើគុកក្រាំងតាចានមើលឃើញជាក់ស្ដែងហើយ មិនឲ្យដឹកក៏វាដឹង កូនខ្ញុំប៉ុនៗនេះសួរវាមើល វាដឹងទាំងអស់ មិនមែនថាមិនដឹងទេ ទៅមើល

សុជាតិៈ	អញ្ចឹងពូគិតថាធ្វើម៉ិចដើម្បីកុំឲ្យរបបនិងវិលមកវិញម្ដងទៀត?

ហៀងៈ	អានិងនៅលើយើងម្នាក់ៗ ប្រជាជនយើងទាំងអស់កុំឲ្យមានរបបនិង ដល់តែយើងស្រុះស្រួលគ្នាទៅ ដល់ពីនិងមកធ្វើម៉ិចកុំឲ្យមាន កុំមានតទៅទៀត ឈប់ត្រឹមនិងទៅ

សុជាតិៈ	តាមមើលទៅ ខ្មែរក្រហមនិងកើតឡើងដោយសារបែកបាក់សាមគ្គីគ្នា ខ្លះរត់ទៅនេះ ខ្លះរត់ទៅនោះតើ

ហៀងៈ	បាទ អានិងវាបែកបាក់រ៉ឺយើងបែកនៅនេះយើងអត់ដឹងណា៎ អានេះដាច់ទៅ អានោះចូលមក យើងអត់ដឹង បើយើងរួបរួមគ្នាទៅដាច់ខាតមិនឲ្យចូលមក អានិងវា

មិុចនិងចូលបាន តែកាលពីមុនអត់ដឹងទេ អានិងវាផ្លាស់ប្តូរសង្គមយើងអត់ដឹងទេ សង្គមនេះសប្បាយកាប់គោកាប់ជ្រូកអីទៅ តែមានគោជ្រូកណាអត់ដែលឃើញផង ប្រហុកអត់ដែលស្គាល់ផង អញ្ចឹងបានថា

សុជាតិ: ពូសព្វថ្ងៃពេលដែលពូមានអារម្មណ៍តឹងតែងផ្លូវចិត្តពូធ្វើមិុចបានជាបាត់?

ហៀង: នៅជួបជុំគ្នាអញ្ចឹងទៅ ចេះតែលេងអញ្ចឹងទៅ ប្រាជ្ញគ្នាលេងទៅ និយាយពីនេះពីនោះទៅ អត់មាននិយាយពីរឿងនយោបាយទេ និយាយពីរឿងរាំងស្ងួតទៅ អានិងវាជ្រះស្រឡះហើយ ហើយបែកគ្នាទៅ ម៉ោង១១-១២ ជួនកាលម៉ោងមួយអីនៅប្រាជ្ញគ្នាលេងនិង

សុជាតិ: ពេលតានតឹងអី និយាយគ្នាទៅធូរវិញទៅ?

ហៀង: បាទ ធូរទៅ រកស៊ីអញ្ចេះ រកស៊ីយ៉ាងមិុចបានតាមជំនាញអញ្ចឹងទៅ គេជំនាញខាង អី គេជំនាញខាងអីអញ្ចឹងទៅ រកស៊ី អត់មាននិយាយរឿងនយោបាយទេ ហើយ បើសិនជានិយាយរឿងនយោយបាយខ្ញុំអត់ចូលចិត្ត មិនលូកដៃទេរឿងនយោបាយ ហើយខ្ញុំ សូម្បីតែសព្វថ្ងៃបងប្អូនក្នុងមូលដ្ឋានក៏ដោយធ្វើមិុចសាមគ្គីគ្នា កុំទាស់គ្នា កុំមើលឃើញផ្ទះនេះលួចផ្ទះនេះ អត់ទេ

សុជាតិ: ពូមនុស្សយើងពេលពិបាកចិត្តហើយស្តាប់ធម៌ស្តាប់អីទៅ អាចធូរស្រាលបានទេពូ?

ហៀង: បាទ សាសនាគ្រាន់តែជួយបំភ្លឺយើង តំរង់យើង

សុជាតិ: បើយើងតឹងចិត្តស្តាប់ធម៌ទៅអាចធូទៅពូ?

ហៀង: តាមវ័យ វ័យចាស់ទៅ បើយើងចូលវត្តចូលវ៉ាទៅស្តាប់ទៅ យើងស្តាប់លោកអីទៅ ធូរទៅ តែបើក្មេងវិញទៅជាស៊ីផ្សេងទៀតទៅ បឋមវ័យផ្សេងទៅ មជ្ឈិមវ័យផ្សេងទៅ មិុចមនុស្សយើងពិបាកណាស់ ក្មេងៗអត់ចូលវត្តទៅ មានក្មេងខ្លះទៀតដែលនៅឆ្ងាយពីវត្តអត់ស្គាល់លោកទៀត នរណាគេនិងវ៉ី?

សុជាតិៈអត់ស្គាល់លោកទៀត?

ហៀង បាទ ក្មេងខ្លះដែលនៅឆ្ងាយពីវត្តណា៎

សុជាតិ: ឥឡូវរឿងឈឺចាប់ពីសម័យខ្មែរក្រហមចេះតែរំខានអារម្មណ៍ពូទេសព្វថ្ងៃនិង?

ហៀង: ខ្ញុំបើបានប្អូនមកបំភ្លឺអញ្ចឹងសប្បាយ សប្បាយ

សុជាតិ: មុនពេលដែលខ្ញុំមករឿងនិងមានចេះតែរំខានពូជាប់ទេ?

ហៀង: អត់ទេ បើពេលយប់គិត មុននិងសំរានគិតមែនទែន មិនមែនមិនគិតទេ គិតខ្លាំង ណាស់ ដូចខ្ញុំជំរាប់អញ្ចឹង បែកបាក់ព្រាត់ប្រាស់ ដល់គេធ្វើបាប ណាមួយខ្លួនឯង

នឹកឃើញភ័យខ្លួន កាលប៉ុលពតគេគូសប៊ិចក្រហមហើយបើកុំតែបានវៀតណាមចូល កុំអីផាប់ វេទនាបំផុត ផ្ទះនេះគេឡើងឡុងទាំងអស់.......អញ្ចឹងខ្ញុំថា ដល់ប្អូនមកសួរនាំ សំណេះសំណាលអញ្ចឹងទៅ សប្បាយណាស់អូន និយាយតាមត្រង់ទៅសប្បាយ ណាស់ អានេះជាការពិត ដូចខ្ញុំបានជំរាបប្អូនអញ្ចឹងថា នយោបាយគឺខ្ញុំអត់និយាយ អញ្ចឹងទេ?

សុជាតិៈ បាទ

ហៀងៈ ខ្ញុំអត់និយាយទេនយោបាយ ខ្ញុំអត់ដឹងទេ.................ក្នុងរាជរដ្ឋាភិបាលមានតែ មួយទេ តែបក្សមានច្រើន ហើយរដ្ឋាភិបាលយើងមានតែមួយទេ មែនទេអូន?

សុជាតិៈ បាទ

ហៀងៈ ច្បាប់តែមួយ

សុជាតិៈ អញ្ចឹងពូកាលពីមុនមកមានដែលពិគ្រោះជាមួយគ្រូពេទ្យព្យាបាលផ្លូវចិត្តដែរទេ?

ហៀងៈ អត់ដែលឃើញគ្រូពេទ្យផ្លូវចិត្តមកផង អត់ទេ

សុជាតិៈ ពូខ្ញុំដូចជាអស់សំនួរអីហើយ ហើយចុងក្រោយពូមានពាក្យពេចអីបន្ថែមទៀតទេ?

ហៀងៈ គ្រាន់តែបានថា បានប្អូនមកសំណេះសំណាលពីពត៍មានរកការពិត ខ្ញុំបានបំភ្លឺប្រាប់ ប្អូនហើយថា ខ្ញុំត្រេចអ អរគុណប្អូនដែលបានស្រាវជ្រាវឯកសារក្នុងរបបធ្វើបាប រកគ្រោះវេទនាក្នុងគ្រួសារណា ហើយដើម្បីស្រាវជ្រាវឲ្យប្អូនក្រោយៗនេះដឹងរបប និងគេធ្វើបាបយ៉ាងម៉ិច រឺគេធ្វើបាបយ៉ាងណា អញ្ចឹងទេ

សុជាតិៈ បាទ ហើយពត៍មានដែលខ្ញុំបានពីពូនេះសំខាន់ណាស់ អាចទុកបានរាប់រយឆ្នាំឯណោះ

ហៀងៈ បាទ ខ្ញុំអរខ្លាំងណាស់

សុជាតិៈ បើសិនជានរណាចង់អានទាក់ទងនិងខ្មែរក្រហមអី កន្លែងខ្ញុំអាចទៅរកអានបានពេល ណាក៏បានដែរ

ហៀងៈ បើខ្មែរយើងអត់មានប្អូនមកស្រាវជ្រាវមកសម្ភាសន៍អី គឺបាត់តែម្តង ហើយកូនចៅ យើងក៏អត់មានដឹងដែរឯកសារនិង បានប្អូនមកអញ្ចឹងជាការអរណាស់ មិនការជួយ ឧបត្ថមអ្វីមួយក៏ខ្ញុំអរគុណដែរ

សុជាតិៈ បាទ ប្រជាជនភាគច្រើនក៏យល់ដូចពូដែរ បើយើងមិនស្រាវជ្រាវទេគឺច្បាស់ជាបាត់ តែម្តងពត៍មាននិង

ហៀងៈ បាទ បានស្រាវជ្រាវអញ្ចឹងទៅត្រេចអរណាស់ ហើយបានឲ្យសៀវភៅខ្ញុំនេះខ្ញុំអរ ណាស់ បានមើលពីការពិតរបស់ឯកសារការស្រាវជ្រាវនេះ ទុកមើលដែរឲ្យដឹងណា

សុជាតិៈ បាទ អរគុណច្រើន

ហៀងៈ បាទ

ចប់